ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សៀវភៅ
# ក្រមងព័ត៌មានសេវាសាធារណៈ


អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ
ទូរសព្ទ ទូរសារ ៖ (៨៥៥) ២៣ ៧២ ៦០ ៨៦
គេហទំព័រ www.mosvy.gov.kh

កែសម្រួល និងបោះពុម្ពដោយ ៖

នាយកដ្ឋានអភិវឌ្ឍន៍គោលនយោបាយ
នៃអគ្គនាយកដ្ឋានគោលនយោបាយសង្គមកិច្ច

សហការឧបត្ថម្ភដោយ ៖

PLAN INTERNATIONAL

អង្គការភ្លែនអន្តរជាតិកម្ពុជា

# សៀវភៅកម្រងព័ត៌មានសេវាសាធារណៈ
# ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# មាតិកា


**បញ្ជីអក្សរកាត់**........................................................................................................................ iii

**ពាក្យបច្ចេកទេស**....................................................................................................................... iv

**អារម្ភកថា**................................................................................................................................ v

**ផ្នែកទី១. អគ្គនាយកដ្ឋានសេវាសង្គមកិច្ច**

១. ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀងទីទ័លក្រគ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ ............................................... ១

២. ការផ្តល់សេវាថែទាំគាំទ្រដល់ជនផ្ទុកមេរោគអេដស៍ជំងឺអេដស៍ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ ............................................... ៣

៣. ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា............................................... ៥

៤. ការទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី ............................................... ៨

៥. ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ............................................... ៩

៦. ការធ្វើមាតុភូមិនិវត្តស្តារនីតិសម្បទានិងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន ...............១១

៧. ការផ្តល់សេវាថែទាំជំនួសចំពោះកុមារ ............................................... ១៣

៨. ការផ្តល់សេវាសុំកូនក្នុងប្រទេស ...............................................១៨

៩. ការផ្តល់សេវាដល់មនុស្សវ័យចាស់សកម្មតាមសមាគម...............................................២២

១០. ការផ្តល់ជំនួយលើការស្វែងរកសេវាសង្គមសម្រាប់គ្រួសារ...............................................២៣

**ផ្នែកទី២. អគ្គនាយកដ្ឋានស្តារសម្បទា**

១១. ការជួយអន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនមានពិការភាព............................................... ២៥

១២. ការផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនមានពិការភាព ............................................... ២៦

១៣. ការផ្តល់សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនមានពិការភាព....... ២៩

១៤. ការផ្តល់របបឧបត្ថម្ភគោលនយោបាយចំពោះជនមានពិការភាពនៅតាមសហគមន៍ .................. ៣១

១៥. ការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន .................. ៣២

១៦. ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន .................. ៣៤

១៧. ការផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់............................................... ៣៨

**ផ្នែកទី៣. អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស**

១៨. ការផ្តល់ការអនុញ្ញាត(អាជ្ញាបណ្ណ)ដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស............................................... ៤២

១៩. ការទុកដាក់កុមារជាមួយគ្រួសារអេចិន្ត្រៃយ៍នៅប្រទេសទទួល............................................... ៤៤

**ផ្នែកទី៤. វិទ្យាស្ថានជាតិសង្គមកិច្ច**

២០. ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពកម្លាំងសេវាសង្គម............................................... ៤៩

២១. ការអប់រំ និងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា ...............................................៥០

**ផ្នែកទី៥. មូលនិធិជនពិការ**
២២. ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនមានពិការភាព និងស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រអ្នកជំងឺរបួសខួរឆ្អឹងខ្នង ..... ៥២
២៣. ការផ្តល់របបគោលនយោបាយផ្នែកពិនិត្យព្យាបាលនិងថែទាំសុខភាពចំពោះជនមានពិការភាពក្រីក្រតាមសហគមន៍ ..... ៥៣
**ផ្នែកទី៦. មូលនិធិជាតិជំនួយសង្គម**
២៤. កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ..... ៥៤
២៥. កម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ..... ៥៥
២៦. ការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ..... ៥៦
២៧. ការផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ..... ៦២

**ឧបសម្ព័ន្ធទី១**
**១./ បញ្ជីឈ្មោះប្រធានអង្គភាព និងមន្ត្រីផ្តល់ព័ត៌មានសេវាសាធារណៈនៃក្រសួង ស.អ.យ.** ..... ៦៩
**ឧបសម្ព័ន្ធទី២**
**២./ បញ្ជីឈ្មោះប្រធានមន្ទីរ ស.អ.យ. និងមន្ត្រីផ្តល់ព័ត៌មានសេវាសាធារណៈទាំង២៥ រាជធានី ខេត្ត** ..... ៧១
**ឧបសម្ព័ន្ធទី៣**
**៣./ បញ្ជីឈ្មោះប្រធានសាខាមូលនិធិជនពិការ និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារាជធានី-ខេត្ត** ..... ៧៤

# បញ្ជីអក្សរកាត់

- ស.អ.យ. សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ប.ជ.ស. បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- ប.ជ.អ. បេឡាជាតិអតីតយុទ្ធជន
- ម.ជ.ជ. មូលនិធិជាតិជំនួយសង្គម
- ម.ជ.ព. មូលនិធិជនពិការ

# ពាក្យបច្ចេកទេស

- ការស្តារនីតិសម្បទា : សំដៅដល់ការស្តារលទ្ធភាពពលកម្មកាយសម្បទានិងវេជ្ជសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងវិញនូវរាងកាយ ស្មារតី សមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ជនរងគ្រោះនិងងាយរងគ្រោះដែលបានបាត់បង់ឬខូចខាតដោយសារជំងឺ ការរងរបួស ការញៀនសារធាតុញៀន ឬពិការភាព ។
- គុណវុឌ្ឍិ : សំដៅដល់ការទទួលស្គាល់ជាផ្លូវការត្រូវផ្តល់ឱ្យហើយការទទួលស្គាល់នោះរក្សាបានចំពោះតែអង្គការណាដែលបង្ហាញសមត្ថភាពរបស់ខ្លួនក្នុងការអនុវត្តន៍ត្រឹមត្រូវនូវភារកិច្ចដែលខ្លួនបានទទួល។
- និវត្តជន : សំដៅដល់ជនត្រូវបានដាក់ឱ្យឈប់សម្រាកតាមច្បាប់ស្តីពីការងារ។
- បៀវត្សហានន្តរស័ក្តិ : សំដៅដល់បៀវត្សមូលដ្ឋាន។
- មាតុភាព : សំដៅដល់ការផ្តល់ជូនស្ត្រីមានពិការភាពជាអតីតយុទ្ធជន ពេលសម្រាលកូន។
- យោធិនពលី : សំដៅដល់យោធិនដែលបានបាត់បង់ជីវិតនៅពេលដែលបានទទួលបញ្ជាទៅប្រយុទ្ធបម្រើការងារប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់និងដោយគ្រោះថ្នាក់ធម្មជាតិ។
- យោធិនមរណៈ : សំដៅដល់យោធិនដែលបានទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិតដោយសារការងារទាំងនោះឬដោយសារជំងឺ។
- រូបវន្ត : សំដៅដល់ការដែលមានរូបប្រាកដដល់ភ្នែក។
- របបសោធននិវត្តន៍ : សំដៅដល់គោលរបបគិតជាទឹកប្រាក់ដែលរដ្ឋត្រូវផ្តល់អោយយោធិនម្នាក់ៗដែលបានបំពេញតាមលក្ខខណ្ឌចូលនិវត្តន៍និងរយៈពេលបំរើការងារ។
- សច្ចាប័ន : សំដៅដល់ការយល់ព្រម ការទទួលស្គាល់ជាផ្លូវការ (ច្បាប់) ឬការយល់ស្របតាមសេចក្តីស្នើសុំជាផ្លូវការ។
- សារវន្ត : សំដៅដល់ការដែលមានសារប្រយោជន៍ដែលសំខាន់ជាមូលដ្ឋានប្រកបដោយខ្លឹមសារ។
- សិទ្ធិវន្ត : សំដៅដល់ជនដែលទទួលផល។
- ហេដ្ឋារចនាសម្ព័ន្ធ : សំដៅដល់មធ្យោបាយនិងទំនាកទំនងផលិតកម្មដែលជាមូលដ្ឋានសង្គមដូចជាផ្លូវ ស្ពាន ព្រែកជីក ទំនប់ ប្រឡាយ រោងចក្រអគ្គិសនី ព្រលានយន្តហោះជាដើម។
- អាទិភាព : សំដៅដល់ការផ្តល់ចំពោះកម្មាភិបាលបំរើការការងារមុនឆ្នាំ១៩៧៩ ត្រូវបានបន្ថែមពី១៥ភាគរយទៅ២០ភាគរយ នៃបៀវត្សហានន្តរស័ក្តិថែមទៀតតាមរយៈពេលបំរើការងារ។

# អារម្ភកថា

កម្រងព័ត៌មានសេវាសាធារណៈ គឺជាឯកសារដ៏មានសារសំខាន់ សម្រាប់ជាជំនួយស្មារតី និងបណ្ដុះនូវពុទ្ធិសម្រាប់អ្នកដឹកនាំ និងមន្ត្រីសង្គមកិច្ចគ្រប់លំដាប់ថ្នាក់ ដែលបំពេញតួនាទីក្នុងនាមជាអ្នកផ្តល់សេវាប្រកបដោយសមធម៌ យុត្តិធម៌ ប្រសិទ្ធភាព និងការទទួលខុសត្រូវ និងសម្រាប់អ្នកដែលមានតម្រូវការសេវាចាំបាច់ក្នុងការស្វែងរកប្រភេទនិងប្រភពនៃសេវាដែលផ្តល់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

សៀវភៅនេះត្រូវបានកែសម្រួលសារជាថ្មី ស្របតាមរចនាសម្ព័ន្ធរបស់ក្រសួង ដោយទទួលបានធាតុចូលបន្ថែមពីគ្រប់ផ្នែក និងអ្នកពាក់ព័ន្ធក្នុងការផ្តល់សេវា។ ខ្លឹមសារសំខាន់ៗ ឆ្លុះបញ្ចាំងអំពីប្រភេទ បែបបទ នីតិវិធី និងឯកសារគាំទ្រចាំបាច់នានា ដើម្បីទទួលបានសេវាពីនីតិបុគ្គល ឬរូបវន្តបុគ្គល ជាអង្គភាព ឬមន្ទីររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ឧបសម្ព័ន្ធនៃសៀវភៅនេះ ក៏រំលេចនូវលេខទូរស័ព្ទទំនាក់ទំនងរបស់ប្រធានអង្គភាព និងមន្ត្រីដែលអាចផ្តល់ព័ត៌មានសេវាសុខុមាលភាពកាន់តែងាយស្រួលនិងឆាប់រហ័សជូនអតិថិជននៅតាម ២៥ រាជធានី-ខេត្ត។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ ឥស្សរជន និងសប្បុរសជននានា ដែលតែងតែជួយឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី បច្ចេកទេស និងហិរញ្ញវត្ថុ រួមចំណែកធ្វើឱ្យវិស័យសង្គមកិច្ចកាន់តែមានការវិវត្តរីកចម្រើនគួរជាទីមោទនៈ និងបានលើកកម្ពស់ជីវភាពនិងសុខុមាលភាពរបស់ប្រជាជននិងសង្គមជាតិទាំងមូលឱ្យកាន់តែប្រសើរឡើង។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សង្ឃឹមយ៉ាងមុតមាំថា គ្រប់អង្គភាព និងអ្នកពាក់ព័ន្ធនឹងបន្តខិតខំអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ថែមទៀត នូវការផ្តល់សេវាទៅតាមព័ត៌មានដែលមានចែងនៅក្នុងសៀវភៅកម្រងព័ត៌មានសេវាសាធារណៈនេះ និងបន្តកែលម្អជាបន្តបន្ទាប់ ដើម្បីបំពេញតម្រូវការអ្នកប្រើប្រាស់សៀវភៅនេះសម្រាប់ជាឯកសារក្នុងការបំពេញការងារ និងជាផែនទីបង្ហាញផ្លូវសម្រាប់អតិថិជនស្វែងរកសេវាសង្គមនៅតាមរាជធានី-ខេត្តដែលខ្លួនរស់នៅផងដែរ។

ថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤

រដ្ឋមន្ត្រី

ជា សុមេធី

## ផ្នែកទី១. អគ្គនាយកដ្ឋានសេវាសង្គមកិច្ច

### ១. ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | កម្មវិធីជំនួយសង្គ្រោះបន្ទាន់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានគាំពារជនរងគ្រោះ<br>ការិយាល័យគាំពារជនរងគ្រោះ និងជនក្រីក្រ<br>ទូរស័ព្ទការិយាល័យ ៖ ០៧០ ៩៧៩ ៧១២ /០១៧ ៧៨៨ ៨៦៦<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មន្ទីរ ស.អ.យ. រាជធានី ខេត្ត |
| គោលបំណង នៃការផ្តល់សេវា | កម្មវិធីជំនួយសង្គ្រោះបន្ទាន់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ ជាសេវាកម្មសាធារណៈរបស់ក្រសួង ស.អ.យ. ត្រូវបានបង្កើតឡើង ក្នុងគោលបំណងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជួយសម្រាលទុក្ខលំបាកក្នុងជីវភាពរស់នៅ និងកាត់បន្ថយភាពរងគ្រោះ និងងាយរងគ្រោះរបស់ប្រជាជនក្រីក្រនៅក្នុងសហគមន៍ |
| មូលដ្ឋានគតិយុត្ត | សារាចរណែនាំលេខ ០០២ ស.អ.យ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីកម្មវិធីជំនួយសង្គ្រោះប្រជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ គ្រោះមហន្តរាយដាយថាហេតុចំណាកស្រុក អនាថា និងវិកលចរិត នៅតាមសហគមន៍ ដោយមានភ្ជាប់គំរូឧបសម្ព័ន្ធលេខ ០១ ដល់លេខ ០៧ |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | ប្រជាជនជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ ជនចំណាកស្រុក ជនអនាថា និងជនវិកលចរិត |
| ស្តង់ដារសេវា | ប្រជាជនជាជនងាយរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះដោយធម្មជាតិ គ្រោះមហន្តរាយដោយយថាហេតុត្រូវបានជួយសង្គ្រោះតាមប្រភេទ និងកម្រិត ដូចខាងក្រោម ៖<br>**ប្រភេទ១ ៖ កម្រិតធ្ងន់**<br>ប្រជាជនរងគ្រោះទីទ័លក្រដាច់ស្បៀង គ្មានមុខរបរគ្មានដីធ្លីជាំជុះ គ្មានជម្រកស្នាក់នៅឬមេគ្រួសារជាស្ត្រីមេម៉ាយមានកូនច្រើនក្នុងបន្ទុក ពុំមានលទ្ធភាពឱ្យកូនទៅសិក្សា ឬមេគ្រួសារជាជនពិការ ជនចាស់ជរា ជនមានជំងឺរ៉ាំរ៉ៃហើយមានក្មេងក្នុងបន្ទុក ពុំមានលទ្ធភាពឱ្យក្មេងទៅសិក្សា។ ត្រូវពិនិត្យលទ្ធភាពផ្តល់ជំនួយគាំទ្រដោយគិតចំនួនសមាជិកគ្រួសារតាមជំហានដូចខាងក្រោម ៖<br>• ជំហានទី ១ ៖ ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាសម្ភារប្រើប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ៥០០.០០០៛ ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួន |

| | |
|---|---|
| | តាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញគ្រឿងឧបភោគបរិភោគដូចជា អង្ករ អំបិល មី ទឹកត្រី ទឹកស៊ីអ៊ីវ សម្ភារប្រើប្រាស់ដូចជា មុង ភួយ និងកៅស៊ូតង់។<br>• ជំហានទី ២ ៖ ត្រូវផ្តល់ជំនួយគាំទ្រសម្រាប់ការស្តារនីតិសម្បទា ដើម្បីជនរងគ្រោះមានស្ថិរភាពស្បៀងសម្រាប់ជីវភាពប្រចាំថ្ងៃក្នុងរយៈពេល ៣០ថ្ងៃ និងផ្តល់សម្ភារសម្រាប់ជួសជុលផ្ទះ ឬសាងសង់ជម្រកស្នាក់នៅបណ្តោះអាសន្នដោយគិតជាថវិកាមិនលើសពីចំនួន ១.៥០០.០០០៛ ក្នុងមួយគ្រួសារ។<br>**ប្រភេទ២ ៖ កម្រិតមធ្យម**<br>ជនរងគ្រោះទីទ័លក្រ ដាច់ស្បៀង ខូចខាត បាត់បង់ទ្រព្យសម្បត្តិផ្ទះសម្បែង ប៉ះពាល់មុខរបរ ឬសុខភាព និងខូចខាតផលដំណាំ។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារ ផ្តល់ជំនួយសង្គ្រោះបន្ទាន់ម្តងគត់ជាសម្ភារប្រើប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ៣០០.០០០៛ ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញស្បៀងអាហារ និងសម្ភារ រួមមាន ៖ អង្ករ អំបិល មុង កន្ទេល ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។<br>**ប្រភេទ៣ ៖ កម្រិតស្រាល**<br>ជនរងគ្រោះដែលទទួលនូវការខូចខាត បាត់បង់ទ្រព្យសម្បត្តិ ឬផលដំណាំតិចតួច។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារ ផ្តល់ជំនួយសង្គ្រោះបន្ទាន់ម្តងគត់ជាសម្ភារៈប្រើប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ២០០.០០០៛ ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញស្បៀងអាហារ និងសម្ភារៈ រួមមាន ៖ អង្ករ អំបិល មី ទឹកត្រី ទឹកស៊ីអ៊ីវ កន្ទេល មុង ភួយ និងកៅស៊ូតង់។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១.សំណើរបស់ប្រធានមន្ទីរ ស.អ.យ. រាជធានី ខេត្ត យោងតាមតារាងគំរូឧបសម្ព័ន្ធ<br>២.សេចក្តីសម្រេចរបស់ក្រសួង ស.អ.យ. |
| យោបល់ | ជំរុញការស្តារនីតិសម្បទា និងសមាហរណកម្មក្នុងសង្គមជាតិ ចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងទទួលផ្លែផ្កានៃការអភិវឌ្ឍប្រកបដោយសមធម៌។ លើកកម្ពស់សេវាសង្គមកិច្ចឈានជាជំហានៗ ពីការផ្តល់ជំនួយសង្គ្រោះទៅជាការរៀបចំឱ្យមានប្រព័ន្ធសន្តិសុខសង្គម ការធានារ៉ាប់រងសង្គមដើម្បីធានាសុខុមាលភាពសង្គមជូនប្រជាជនតាមលទ្ធភាពសេដ្ឋកិច្ចជាតិ ដោយចាត់ទុកជាយុទ្ធសាស្រ្តសំខាន់នៃគោលការណ៍បែងចែកភោគផលដោយសមធម៌។ |

## ២.ការផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗ នៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានគាំពារជនរងគ្រោះ<br>ការិយាល័យគាំពារជនអនាថា និងជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍<br>ទូរស័ព្ទការិយាល័យ ៖ ០៩៨ ៨០៤ ៩៦៦ / ០១៧ ៧៨៨ ៨៦៦<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មន្ទីរ ស.អ.យ. រាជធានី ខេត្ត |
| គោលបំណងនៃការផ្តល់សេវា | ដើម្បីទប់ស្កាត់ការរីករាលដាលដោយសារមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយមេរោគអេដស៍ ជំងឺអេដស៍និងជំងឺកាចសាហាវផ្សេងៗ និងជួយឱ្យជនរងគ្រោះដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗទទួលបាននូវសេវាថែទាំ និងគាំទ្រប្រកបដោយប្រសិទ្ធភាព។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមណ្ឌលរបស់រដ្ឋ<br>- ប្រកាសលេខ ១២២៨ ស.អ.យ. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព និងតួនាទី ភារកិច្ចរបស់ការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ<br>- ប្រកាសលេខ ០១០ ស.អ.យ. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការចាត់តាំងក្រុមការងារដើម្បីអនុវត្តកម្មវិធីមូលនិធិសកលជុំទី៧<br>- ប្រកាសលេខ ១១៩ ស.អ.យ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសលេខ ៣៣៣ ស.អ.យ. ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ |
| ស្តង់ដារសេវា | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ត្រូវទទួលសេវាថែទាំ និងគាំទ្រដូចខាងក្រោម ៖ |

| | |
|---|---|
| | ១-ទារក កុមារមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលត្រូវទទួលរបបឧបត្ថម្ភដូចខាងក្រោម៖<br>- ទារកអាយុ ២ឆ្នាំចុះ ទទួលរបបថ្លៃទឹកដោះគោ ក្នុង១ខែ ៦០.០០០៛ និងថ្លៃសម្លៀកបំពាក់ សម្ភារដំណេក អនាម័យ និងព្យាបាល ១ដងក្នុង ១ឆ្នាំ ១២០.០០០៛ ( ទទួលពេលដើមឆ្នាំ )<br>- កុមារអាយុលើសពី ២ឆ្នាំ ទទួលរបបឧបត្ថម្ភថ្លៃម្ហូបអាហារ ១ខែ ៤៥.០០០៛ ថ្លៃសម្លៀកបំពាក់ សម្ភារសិក្សា កីឡា សម្ភារដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១ដង ក្នុង១ឆ្នាំ ១២០.០០០៛( ទទួលពេលដើមឆ្នាំ )<br>- ទារក កុមារទទួលរបបបំប៉នសុខភាពបន្ថែមក្នុង ១ខែ ២០.០០០៛<br>- ទារក កុមារអាយុ ៥ឆ្នាំចុះ ពេលទទួលមរណភាពត្រូវបានឧបត្ថម្ភម្តងគត់ សម្រាប់រៀបចំពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ៦ខែ (២៧០.០០០ ៛)<br>- កុមារអាយុលើសពី ៥ឆ្នាំឡើង ទទួលមរណភាពឧបត្ថម្ភម្តងគត់សម្រាប់រៀបចំពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ ១២ខែ (៥៤០.០០០៛ )<br>២- កុមាររងផលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺអេដស៍ កុមារកំព្រា កុមារមានពិការភាពធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ ជនមានពិការភាពមានជំងឺអេដស៍ ជនពិការ អនាថាមានជំងឺអេដស៍។ កុមារមានអាយុក្រោម ៥ឆ្នាំ គ្រួសារមានសមាជិករស់នៅជាមួយ មេរោគអេដស៍ ឬទទួលផលប៉ះពាល់ដោយជំងឺអេដស៍ គ្រួសារដែលមានអាណា-ព្យាបាលជាមនុស្សចាស់ និងមិនអាចមានសមត្ថភាពធ្វើការងារ ឬគ្រួសារដែលមានកុមារជាមេគ្រួសារ ត្រូវទទួលកញ្ចប់ស្បៀងអាហារបន្ទាន់មាន ៖<br>• អង្ករចំនួន ៣០ គីឡូក្រាម<br>• ប្រេងឆា ចំនួន ១ លីត្រ<br>• អំបិលអ៊ីយ៉ូត ចំនួន ១/២ គីឡូក្រាម<br>• ប្រូតេអ៊ីនបន្ថែម ( ស៊ុត សៀង សាច់ងៀត ឬត្រីខកំប៉ុង ) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១. ទម្រង់របាយការណ៍<br>២.ទម្រង់ស្ថិតិជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ<br>៣.ទម្រង់ទិន្នន័យជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗដែលទទួលបានសេវាថែទាំ និងគាំទ្រ<br>៤. សំណើរបស់ប្រធានមន្ទីរ ស.អ.យ. រាជធានី ខេត្ត |
| យោបល់ | ដើម្បីឆ្លើយតបនឹងការទប់ស្កាត់ ការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ ៖<br>- ត្រូវរៀបចំអនុក្រឹត្យ ស្តីពីការផ្តល់របបជំនួយឧបត្ថម្ភដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ ដែលទីទ័លក្រ គ្មានទីពឹង និងគ្មានជម្រក<br>- បង្កើតក្រុមការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃ |

| | |
|---|---|
| | - សិក្សាស្រាវជ្រាវពីបញ្ហាប្រឈម និងរកដំណោះស្រាយដែលសមស្របដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវ ផ្សេងៗ |

## ៣.ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា

| ឈ្មោះសេវា | ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា |
|---|---|
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានគាំពារជនរងគ្រោះ<br>ការិយាល័យគាំពារជនអនាថា និងជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍<br>ទូរស័ព្ទការិយាល័យ ៖ ០៩៨ ៨០៤ ៥៦៦ /០១៧ ៧៨៨ ៨៦៦<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មន្ទីរ ស.អ.យ. រាជធានី ខេត្ត |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការស្នាក់នៅជាបណ្តោះអាសន្ន ហូបចុក ថែទាំសុខភាព ព្យាបាលជំងឺ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ធ្វើការបញ្ជូនបន្តទៅអង្គការដៃគូ និងសមាហរណកម្មទៅសហគមន៍វិញ។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បកចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- សេចក្តីណែនាំលេខ ០១ សណន.គជអ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ស្តីពីការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថា<br>- ផែនការសកម្មភាពស្តីពីការដោះស្រាយបញ្ហាជនអនាថាលេខ ០១ គ.ជ.អ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩<br>- កិច្ចព្រមព្រៀងលេខ ០០៦ គ.ជ.អ/ស.អ.យ. ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីកិច្ចសហការប្រតិបត្តិការរវាងអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា (អ.គ.អ.) រាជធានី ខេត្ត<br>- សេចក្តីសម្រេចស្តីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា<br>- ប្រកាសលេខ ៤៨២ ស.អ.យ. ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែប្រែមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈពោធិ៍សែនជ័យ ទៅជាមណ្ឌលសំចតសង្គមកិច្ច រាជធានីភ្នំពេញ |

| | |
|---|---|
| | - សារាចរណែនាំលេខ ០០២ ស.អ.យ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីកម្មវិធីជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុ ចំណាកស្រុក អនាថា និងវិកលចរិតនៅតាមសហគមន៍ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនរងគ្រោះដែលស្ម័គ្រចិត្តមកទទួលសេវា ៖<br>- ជនចាស់ជរា និងជនមានពិការភាពគ្មានទីពឹង<br>- ជនអនាថា<br>- ជនវិកលចរិត<br>- ទុរគតជន<br>- ស្ត្រី កុមាររងគ្រោះដោយសារការជួញដូរផ្លូវភេទ និងពលកម្ម<br>- អ្នកប្រើប្រាស់សារធាតុញៀន<br>- ជនរងគ្រោះ និងងាយរងគ្រោះផ្សេងៗទៀត |
| ស្តង់ដារសេវា | ជនអនាថាទទួលបានរបបគោលនយោបាយស្នាក់នៅបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅមូលដ្ឋានមានដូចខាងក្រោម ៖<br>**ប្រភេទ១ ៖**<br>- របបម្ហូបអាហារស្នាក់នៅក្នុងមជ្ឈមណ្ឌល ៥.០០០៛ ម្នាក់ក្នុងមួយថ្ងៃ<br>- របបប៉ប៉នសុខភាពចំពោះជនអនាថាស្នាក់នៅក្នុងមជ្ឈមណ្ឌល ២០.០០០៛/ខែ<br>- របបសម្លៀកបំពាក់ចំពោះជនមានពិការភាព ជនអនាថា និងជនចាស់ជរាគ្មានទីពឹងស្នាក់នៅក្នុង មជ្ឈមណ្ឌល ១២០.០០០៛/ឆ្នាំ (ទទួលបាននៅដើមឆ្នាំ)<br>- របបបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈចំពោះជនមានពិការភាព ជនអនាថា ដែលមានជំងឺអេដស៍ ៣៩០.០០០៛ ក្នុងមួយវគ្គ (រយៈពេល៣ខែ)<br>- របបរៀបចំពិធីបុណ្យសពជនអនាថា ជនមានពិការភាព និងចាស់ជរាគ្មានទីពឹង ស្នាក់នៅក្នុងមជ្ឈមណ្ឌលទទួលមរណភាព ៥៤០.០០០៛ (១ដងគត់)<br>- របបសមាហរណកម្មវិលទៅសហគមន៍វិញ ដើម្បីធ្វើទុនប្រកបមុខរបរ កសាងជីវភាពគ្រួសារដោយខ្លួនឯង ៨១០.០០០៛ (១ដងគត់)<br>**ប្រភេទ២ ៖**<br>ជនរងគ្រោះ និងងាយរងគ្រោះ ចំណាកស្រុកដោយប្រថុយប្រថាន ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាសម្ភារប្រើប្រាស់ និងស្បៀងអាហារ ដោយគិតជាថវិកាមិនលើសពីចំនួន ៣០០.០០០៛ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញគ្រឿងឧបភោគបរិភោគដូចជា អង្ករ អំបិល មី ទឹកត្រី ទឹកស៊ីអ៊ីវ និងសម្ភារៈប្រើប្រាស់ដូចជា មុង ភួយ និងកៅស៊ូតង់។<br>**ប្រភេទ៣ ៖**<br>ជនអនាថា ជាជនទីទ័លក្រ គ្មានទីជម្រក តែលតោលគ្មានទីពឹងស្នាក់នៅតាមទីសាធារណៈ តំបន់ទេសចរណ៍ ឬទីប្រជុំជននានា ក្នុងរាជធានី ខេត្ត ដោយធ្វើសកម្មភាពដើរសុំទាន ជូតកញ្ចក់រថយន្ត លក់ផ្កា ឬលក់កាសែតតាមស្តុប។ល។ ត្រូវពិនិត្យផ្តល់ជំនួយគាំទ្រ ពិគ្រោះយោបល់ និងជំនួយសង្គ្រោះបន្ទាន់ជាស្បៀងអាហារ និង |

| | |
|---|---|
| | មធ្យោបាយដោយគិតជាថវិកាមិនលើសពីចំនួន ៣០០.០០០៛ក្នុងមួយគ្រួសារ (ចំពោះជនអនាថាដែលយល់ព្រមធ្វើសមាហរណកម្មទៅក្នុងសហគមន៍)<br>**ប្រភេទ១៤ ៖**<br>ជនវិកលចរិត ជាជនដែលមានវិបត្តិផ្នែកអារម្មណ៍ និងការគិត ដែលកើតឡើងជាប្រចាំ និងដើរអនាថា (គ្មានសាច់ញាតិថែទាំ) ត្រូវស្វែងរកសេវាគាំទ្រនានារួមទាំងការស្នាក់នៅ ហូបចុក និងសេវាសុខភាពគិតជាថវិកាមិនលើសពី ចំនួន ៣០០.០០០៛ ក្នុងមួយនាក់ និងថវិកាតាមលទ្ធភាពជាក់ស្តែង។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១. សំណើរបស់ប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរ ស.អ.យ. រាជធានី ខេត្ត<br>២. សេចក្តីសម្រេចរបស់ក្រសួង |
| យោបល់ | ការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថាក្នុងគោលបំណងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ព្រមទាំងធ្វើការទប់ស្កាត់នូវលំហូរចូលនៃជនអនាថាមកទីក្រុង ឬទីប្រជុំជន និងឆ្លងដែនទៅប្រទេសជិតខាង។ ដូច្នេះ ក្រសួង ស.អ.យ. មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖<br>- បង្កើតឱ្យមានយុទ្ធសាស្ត្ររួម សម្រាប់ដោះស្រាយបញ្ហាជនអនាថា ដោយរួមបញ្ចូលការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងបង្ការទប់ស្កាត់ការវិលត្រឡប់មកសុំទានវិញ<br>- ពង្រឹងពង្រីកបណ្តាញការងារសម្រាប់ជនអនាថានៅគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សេវាដល់ជនទាំងនោះ ឱ្យមានលំនឹងក្នុងការកសាងជីវភាពរស់នៅដោយខ្លួនឯង<br>- ផ្តល់ឱកាសឱ្យជនអនាថាមានជម្រកសុវត្ថិភាព ស្នាក់នៅបណ្តោះអាសន្ន ដើម្បីទទួលបាន ការផ្គត់ផ្គង់ជីវភាពការ ថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងធ្វើការដឹកជញ្ជូនជនទាំងនោះ ឱ្យបានដល់មូលដ្ឋានគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ<br>- កសាងផែនការថវិកាប្រចាំឆ្នាំ សម្រាប់ចំណាយលើការងារសេវាដល់ជនអនាថា ដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗទៀត<br>ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តគោលការណ៍ផែនការកម្មវិធី និងគម្រោងនានា ព្រមទាំងគ្រប់គ្រងស្ថិតិ និងបូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថាប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល |

## ៤.ការទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី

| | |
|---|---|
| ឈ្មោះសេវា | សេវាទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានគាំពារជនរងគ្រោះ<br>ការិយាល័យគាំពារជនអនាថា និងជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍<br>ទូរស័ព្ទការិយាល័យ ៖ ០៩៨ ៨០៤ ៤៦៦ /០១៧ ៧៨៨ ៨៦៦<br>អាសយដ្ឋាន៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មន្ទីរ ស.អ.យ. រាជធានី ខេត្ត |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការស្នាក់នៅ ហូបចុក ថែទាំសុខភាព ព្យាបាលជំងឺ ស្តារនីតិសម្បទា និងធ្វើការសមាហរណកម្មទៅសហគមន៍វិញ។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បកចុះថ្ងៃទី២៦ តុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- សំណើសុំគោលការណ៍បង្កើតមជ្ឈមណ្ឌលទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | ជនរងគ្រោះដែលស្ម័គ្រចិត្តមកទទួលសេវា៖<br>- ជនវិបល្លាសស្មារតី<br>- ជនអនាថាគ្មានទីពឹង |
| ស្តង់ដារសេវា | - ជនវិបល្លាសស្មារតីទទួលបានរបបគោលនយោបាយស្នាក់នៅព្យាបាលស្តារនីតិសម្បទា និងធ្វើសមាហរណកម្មទៅសហគមន៍ទទួលបានរបបគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការហូបចុកប្រចាំថ្ងៃ ៥.០០០៛ (ប្រាំពាន់រៀល) មួយនាក់ក្នុងថ្ងៃ<br>- ការព្យាបាលដោយក្រុមគ្រូសារពេទ្យឯកទេសប្រចាំថ្ងៃ និងការពិនិត្យវាយតម្លៃ ២ដងក្នុង១សប្តាហ៍ ការស្តារនីតិសម្បទាជាប្រចាំថ្ងៃតាមបែបបច្ចេកទេសវេជ្ជសាស្ត្រ និងសហគមន៍ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ១. ឯកសារពិនិត្យបញ្ជាក់ និងបញ្ជូនពីអាជ្ញាធរ<br>២. លិខិតវាយតម្លៃពីក្រុមគ្រូពេទ្យឯកទេសពីផ្នែកវិកលវិទ្យា<br>៣. ទម្រង់វាយតម្លៃរបស់មណ្ឌល |
| យោបល់ | ការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថាក្នុងគោលបំណងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ព្រមទាំងធ្វើការទប់ស្កាត់នូវលំហូរចូលនៃជនអនាថាមកទីក្រុង ឬទីប្រជុំជន និងឆ្លងដែនទៅប្រទេសជិតខាង។ ដូច្នេះ ក្រសួង ស.អ.យ. មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖ |

| | |
|---|---|
| | - បង្កើតឱ្យមានយុទ្ធសាស្ត្ររួម សម្រាប់ដោះស្រាយបញ្ហាជនអនាថា ដោយរួមបញ្ចូលការ ស្តារនីតិសម្បទា ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងបង្ការ និងទប់ស្កាត់ការវិលត្រឡប់មកសុំទានវិញ<br>- ពង្រឹងពង្រីកបណ្តាញការងារសម្រាប់ជនអនាថានៅគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សេវាដល់ជនទាំងនោះឱ្យមានលំនឹងក្នុងការកសាងជីវភាពរស់នៅដោយខ្លួនឯង<br>- ផ្តល់ឱកាសឱ្យជនអនាថាមានជម្រកសុវត្ថិភាព ស្នាក់នៅបណ្តោះអាសន្ន ដើម្បីទទួលបានការផ្គត់ផ្គង់ជីវភាពការថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងធ្វើការដឹកជញ្ជូនជនទាំងនោះឱ្យបានដល់មូលដ្ឋានគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ<br>- កសាងផែនការថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើការងារសេវាដល់ជនអនាថាដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗទៀត<br>- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តគោលការណ៍ផែនការកម្មវិធី និងគម្រោងនានាព្រមទាំងគ្រប់គ្រងស្ថិតិ និងបូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថាប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល |

## ៥. ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ

| ឈ្មោះសេវា | សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ |
|---|---|
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានគាំពារជនរងគ្រោះ<br>អាសយដ្ឋាន៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ៖ ០៩២ ៥៧០ ១៤៤ /០១៧ ៧៨៨ ៨៦៦<br>❖ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត<br>អាសយដ្ឋាន៖ ផ្លូវ សុខភាព ផ្ទះលេខ ១២ ភូមិប្រជាធម្មកើត សង្កាត់ អូរឬស្សី ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ<br>ទូរសព្ទ៖ ០៥៤ ៩៦៧ ១៤១ / ០១២ ៧២៥ ០៥៧<br>អ៊ីមែល៖ chramanith@gmail.com<br>❖ មន្ទីរ ស.អ.យ. រាជធានី ខេត្ត |
| គោលបំណងនៃការផ្តល់សេវា | ជួយសង្គ្រោះដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទទួលបាននូវការស្នាក់នៅ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍ |

| | |
|---|---|
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះថ្នាក់នៅក្នុងមណ្ឌលរដ្ឋ<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- ប្រកាសលេខ ២១៧៨ ស.អ.យ. ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្ត ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>- ប្រកាសលេខ ១២៧៤ ស.អ.យ. ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើសមាហរណកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល<br>- នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីការផ្តល់ការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះជាបុរសដោយអំពើជួញដូរមនុស្ស ខែឧសភា ឆ្នាំ២០១២<br>- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្សរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខែធ្នូ ឆ្នាំ ២០១០<br>- សារាចរណែនាំលេខ ០១១ ស.អ.យ. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដែលបានស្នាក់នូវក្នុងមជ្ឈមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍<br>- ប្រកាសលេខ ៨៥២ ស.អ.យ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ លើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>- សៀវភៅបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាស លេខ ២៩០ ស.អ.យ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឲ្យនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>- ប្រកាសលេខ ១២៨ ស.អ.យ. ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតមជ្ឈមណ្ឌលសំចតប៉ោយប៉ែត |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនរងគ្រោះដោយសារការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ |
| ស្តង់ដារសេវា | ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានទទួលការថែទាំ របបស្នាក់នៅ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍ដូចខាងក្រោម ៖<br>- របបម្ហូបអាហារ ស្នាក់នៅក្នុងមជ្ឈមណ្ឌល ១៥០.០០០៛/ខែ (រយៈពេល ០៣ខែ) |

| | |
|---|---|
| | - របបសម្លៀកបំពាក់ សម្ភារសិក្សា កីឡា សម្ភារដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១២០.០០០៛ (ទទួលពេលដើមឆ្នាំ)<br>- របប ១វគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ សម្រាប់រយៈពេលខ្លី ០៣ខែ ទទួលបាន ៣៩០.០០០៛ ក្នុងមួយវគ្គ<br>- របបសមាហរណកម្មវិលទៅសហគមន៍វិញ ដើម្បីធ្វើទុនប្រកបមុខរបរ កសាងជីវភាពគ្រួសារដោយខ្លួនឯង ៨១០.០០០៛ (១ដងគត់) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១. សំណើរបស់ប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរ ស.អ.យ. រាជធានី ខេត្ត<br>២. សេចក្តីសម្រេចរបស់ក្រសួង ស.អ.យ. |
| យោបល់ | ការអនុវត្តផែនការសកម្មភាពគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងគោលបំណងការពារស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍វិញដូច្នេះក្រសួង ស.អ.យ. ជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖<br>- បង្កើតផែនការសកម្មភាពសម្រាប់គាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយក្នុងនោះរួមបញ្ចូលទាំងការផ្តល់ជម្រក ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងមាតុភូមិនិវត្តន៍ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស<br>- កសាងផែនការថវិកាប្រចាំឆ្នាំសម្រាប់ការចំណាយលើការផ្តល់សេវាដល់ជនរងគ្រោះដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួង ស.អ.យ និងទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗ<br>- ត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលការអនុវត្តផែនការកម្មវិធី និងគម្រោងនានា គ្រប់គ្រងទិន្នន័យ និងបូកសរុបលទ្ធផលការងារកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល |

## ៦. ការធ្វើមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន

| | |
|---|---|
| ឈ្មោះសេវា | មាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានគាំពារជនរងគ្រោះ<br>ការិយាល័យគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ<br>លេខទូរស័ព្ទការិយាល័យ ៖ ០៩២ ៥៧០ ១៤៥ /០១៧ ៧៨៨ ៨៦៦<br>អាសយដ្ឋាន៖ អគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |

| | |
|---|---|
| គោលបំណង នៃការផ្ដល់សេវា | ➢ **ការធ្វើមាតុភូមិនិវត្តន៍(ការទទួល និងបញ្ជូន)ដោយអំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន**<br>– ប្រសិទ្ធភាពក្នុងការទទួលជនរងគ្រោះ ក្រោយពីអន្តោគមន៍វិបត្តិ<br>– ប្រសិទ្ធភាពក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ទៅប្រទេសដើមវិញ<br>➢ **ស្តារនីតិសម្បទាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន**<br>– ប្រសិទ្ធភាពក្នុងការផ្តល់សេវាផ្នែកវេជ្ជសាស្ត្រ<br>– ប្រសិទ្ធភាពក្នុងការប្រឹក្សាយោបល់ និងព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះ<br>– ប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ<br>– ប្រសិទ្ធភាពក្នុងការផ្តល់សេវាផ្នែកច្បាប់<br>– ប្រសិទ្ធភាពក្នុងការពង្រឹងសេដ្ឋកិច្ច<br>➢ **សមាហរណកម្មជនរងគ្រោះទៅសហគមន៍ដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន**<br>– ប្រសិទ្ធភាពក្នុងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ<br>– ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះមិនឱ្យធ្លាក់ខ្លួនសារជាថ្មី<br>– ប្រសិទ្ធភាពក្នុងការផ្តល់នូវសេចក្តីសង្ឃឹម និងបំណិនជីវិតដល់ជនរងគ្រោះ<br>– ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះ ឱ្យក្លាយជាសមាជិកថ្មី រស់នៅក្នុងសហគមន៍<br>– ប្រសិទ្ធភាពក្នុងការជួយបង្កើនភាពនឹងនរផ្លូវកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍<br>– ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះ ដើម្បីទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍សារជាថ្មី |
| មូលដ្ឋានគតិយុត្ត | - ច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ<br>- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួល ជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខែធ្នូ ឆ្នាំ ២០១០<br>- នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ឆ្នាំ២០១៩<br>- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឆ្នាំ២០០៩<br>- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ឆ្នាំ២០១៤<br>- សារាចរណែនាំលេខ ០១១ ស.អ.យ. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទដែលបានស្នាក់នូវក្នុងមជ្ឈមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ |

| | |
|---|---|
| | - សេចក្តីសម្រេចលេខ១០៧ ស្តីពីគោលការណ៍ការពារសិទ្ធិជនរងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧<br>- គោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨<br>- សេចក្តីណែនាំស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ២០១០<br>- គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | រូបវន្តបុគ្គល (ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន) |
| ស្តង់ដារសេវា | - ការស្នាក់នៅក្នុងមជ្ឈមណ្ឌលរយៈពេលខ្លីសមាហរណកម្មទៅគ្រួសារ សហគមន៍ និងមណ្ឌល<br>- ការស្នាក់នៅក្នុងមជ្ឈមណ្ឌលរយៈពេលវែង(ស្ថានីតិសម្បទា) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១.ទម្រង់សម្ភាសន៍ និងកំណត់អត្តសញ្ញាណបឋមដើម្បីផ្តល់សេវាសមស្របដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>លិខិតបញ្ជូន៖<br>២.ទម្រង់ទទួលនិងស្វែងរកគ្រួសារ<br>៣.ទម្រង់ផែនការករណី<br>៤.ទម្រង់ប៉ាន់ប្រមាណ<br>៥.ទម្រង់សមាហរណកម្ម<br>៦.ទម្រង់ព័ត៌មានត្រឡប់<br>៧.ទម្រង់តាមដាន និង<br>៨.ទម្រង់បិទករណី |
| យោបល់ | |

## ៧.ការផ្តល់សេវាថែទាំជំនួសចំពោះកុមារ

| ឈ្មោះសេវា | **សេវាថែទាំជំនួសចំពោះកុមារ** |
|---|---|
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានកិច្ចការពារកុមារ<br>ការិយាល័យកិច្ចការសេវាថែទាំជំនួសចំពោះកុមារ<br>លេខទូរស័ព្ទការិយាល័យ ០១៥ ៧៣៣ ១៦៨ |

| | |
|---|---|
| | អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មជ្ឈមណ្ឌលទារក និងកុមារជាតិ<br>លេខទូរសព្ទមជ្ឈមណ្ឌល ០១៧ ៤១១ ៤៥៨ / ០១០ ៤១១ ៤៥៨<br>អាសយដ្ឋាន ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>❖ រដ្ឋបាលរាជធានី ខេត្ត<br>❖ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត<br>❖ ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម នៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ |
| **គោលបំណង នៃការផ្តល់សេវា** | ផ្តល់កិច្ចការពារ និងសេវាចំពោះកុមារដែលរស់ក្នុងស្ថានភាពងាយរងគ្រោះមួយឬច្រើនប្រភេទដែលត្រូវចាត់ទុកជាប្រភេទកុមារកិច្ចការពារពិសេស ឬកុមារប្រឈមនឹងគ្រោះថ្នាក់<br>***១.កុមារដែលថែទាំដោយសាច់ញាតិ***<br>- កុមារស្ថិតក្នុងស្ថានភាពមួយដែលសមាជិកក្នុងក្រុមគ្រួសារធំមួយទទួលយកកុមារមកចិញ្ចឹមនៅក្នុងគ្រួសាររបស់ខ្លួន ដូចជា ជីដូនជីតា ម្តាយមីង ឪពុកធំ ឪពុកមា ឬជាសាច់ញាតិដទៃទៀតរបស់កុមារ<br>- កុមារទទួលបានការព្រមព្រៀងជាលាយល័ក្ខណ៍អក្សររវាងឪពុកម្តាយបង្កើត និងសាច់ញាតិ តាមរយៈអាជ្ញាធរ ឬអាជ្ញាធរថ្នាក់កណ្តាល ហើយនិងអង្គការណាមួយ<br>***២.កុមារដែលថែទាំដោយឪពុកម្តាយធម៌***<br>- កុមារទទួលបានការថែទាំដោយគ្រួសារមួយដែលពុំមែនជាសាច់ញាតិរបស់កុមារ<br>- កុមារទទួលបានការមើលថែទាំជាបណ្តោះអាសន្ន រយៈពេលខ្លី ឬវែងតាមហេតុផលសមស្រប និងត្រៀមបង្រួបបង្រួមកុមារឱ្យបានទៅរស់នៅជួបជុំជាមួយសាច់ញាតិ ឬគ្រួសារបង្កើតវិញ<br>- កុមារទទួលបានការថែទាំដោយផ្អែកលើកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរដែលធ្វើឡើងរវាងឪពុកម្តាយបង្កើត ឪពុកម្តាយធម៌ អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរថ្នាក់កណ្តាល និងអង្គការណាមួយ<br>***៣.កុមារដែលថែទាំនៅតាមទីវត្តអារាម ឬទីកន្លែងជំនឿសាសនា នានា***<br>- កុមារទទួលបានការថែទាំជំនួសនៅតាមទីវត្តអារាម ឬទីកន្លែងជំនឿសាសនា នានា ដូចជា ព្រះសង្ឃ ដូនជី និងអាចារ្យ<br>- កុមារទទួលបាននូវចំណីអាហារ ជម្រក ការអប់រំ ជាដើម<br>***៤.កុមារដែលថែទាំនៅតាមផ្ទះជាក្រុម***<br>- ចាត់ចែងរៀបចំឱ្យកុមាររស់នៅជុំគ្នាជាក្រុមដោយកំណត់ចំនួនជាក់លាក់ ក្រោមការថែទាំដោយបុគ្គលជាឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ដែលពុំមែនជាសាច់ញាតិរបស់កុមារនៅក្នុងផ្ទះជាមួយគ្នា<br>- ទទួលបានការថែទាំនៅក្នុងសហគមន៍មួយ ប៉ុន្តែពុំមែននៅក្រោមការចាត់ចែងគ្រប់គ្រងរបស់សហគមន៍ទេ |

| | |
|---|---|
| | - ទទួលបានការស្នាក់នៅ ហូបចុក រៀនសូត្រ និងទទួលបានដំណោះស្រាយ សេចក្តីត្រូវការជាក់ស្តែងរបស់កុមារ ដោយផ្តល់ការថែទាំរយៈពេលខ្លី និងរយៈពេលវែងតាមហេតុផលសមស្រប<br>***៥.កុមារនៅក្នុងមជ្ឈមណ្ឌលថែទាំ***<br>- ចាត់ចែងរៀបចំឱ្យកុមាររស់នៅជុំគ្នាជាក្រុមក្រោមការថែទាំដោយបុគ្គលិកមណ្ឌល<br>- ទទួលបានការថែទាំពេញលេញក្នុងមួយរយៈពេលសមស្រប<br>- ទទួលបានការថែទាំ របបគោលនយោបាយដោយរដ្ឋ និងអង្គការមិនមែន<br>- រដ្ឋាភិបាលដោះស្រាយសេចក្តីត្រូវការជាក់ស្តែងរបស់កុមារដោយផ្តល់ការថែទាំរយៈពេលខ្លី និង រយៈពេលវែងតាមហេតុផលសមស្រប |
| **មូលដ្ឋានគតិយុត្ត** | - គោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ (២០១៩-២០២៩)<br>- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ<br>- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌល និងនៅតាមសហគមន៍<br>- ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ<br>- ប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិនិងឪពុកម្តាយធម៌<br>- ប្រកាសលេខ២៣៣ ស.អ.យ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ<br>- ប្រកាសស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំការអនុញ្ញាតបង្កើតមណ្ឌលថែទាំកុមារ<br>- គោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្ម ការបង្វែរកន្លែងថែទាំ និងបិទកន្លែងថែទាំកុមារ<br>- អនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ<br>- អនុក្រឹត្យលេខ៣៤ អនក្រ.បក ស្តីពីការប្រគល់មុខងារការប្រគល់គ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងឃុំ<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ<br>- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា<br>- ប្រព័ន្ធវិញ្ញាបនបត្រអង្គការសុវត្ថិភាពកុមារ |

| | |
|---|---|
| | - សៀវភៅបទដ្ឋាន និងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រសម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះដទៃទៀត |
| **អតិថិជនដែលមានសិទ្ធិទទួលសេវា** | កុមារដែលរស់នៅក្នុងមណ្ឌលរបស់រដ្ឋ និងកុមារដែលបានធ្វើសមាហរណកម្មទៅរស់នៅក្នុងគ្រួសារ និងសហគមន៍មានដូចជា ៖<br>១. កុមារកំព្រា<br>២. កុមារដែលត្រូវបានបោះបង់ចោលតាមមន្ទីរពេទ្យ និងទីសាធារណៈ<br>៣. កុមារដែលទទួលផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ និងមានជំងឺអេដស៍<br>៤. កុមារដែលទទួលរងរំលោភផ្លូវភេទ រូបរាងកាយ ផ្លូវចិត្ត<br>៥. កុមារអនាថាតាមចិញ្ចើមថ្នល់<br>៦. កុមារមានទំនាស់ជាមួយច្បាប់<br>៧. កុមារដែលរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវភេទ ឬទម្រង់ពលកម្មប្រកបដោយគ្រោះថ្នាក់<br>៨. កុមារដែលមានពិការភាព<br>៩. កុមារញៀនសារធាតុញៀន<br>១០. កុមារដែលមិនបានទទួលនូវតម្រូវការផ្នែករូបវន្តជាមូលដ្ឋាន<br>១១. កុមាររងអំពើហិង្សាក្នុងគ្រួសារ<br>១២. ការថែទាំកុមារនៅតាមគ្រួសារ សាច់ញាតិ គ្រួសារធម៌ និងផែនការអចិន្ត្រៃយ៍<br>១៣. ការថែទាំនៅតាមវត្តអារាមព្រះពុទ្ធសាសនា និងទីកន្លែងសាសនានានា<br>១៤. ការថែទាំកុមារនៅតាមមណ្ឌលថែទាំ<br>១៥. ការថែទាំកុមារនៅតាមផ្ទះជាក្រុម<br>១៦. កុមារដែលជាកម្មវត្ថុសុំកូនក្នុងប្រទេស |
| **ស្តង់ដារសេវា** | - កុមារដែលរស់នៅក្នុងមណ្ឌលថែទាំរបស់រដ្ឋ៖<br>កុមារកំព្រាដែលស្នាក់នៅមណ្ឌលថែទាំរបស់រដ្ឋក្នុងមួយនាក់ទទួលបានរបបគោលនយោបាយ ៥.០០០៛ (ប្រាំពាន់រៀល) ក្នុងមួយថ្ងៃ ស្មើនឹង ១៥០.០០០៛ (ដប់ប្រាំម៉ឺនរៀល) ក្នុងមួយខែ<br>- កុមារកំព្រាដែលស្នាក់នៅក្នុងមណ្ឌលថែទាំរបស់រដ្ឋមានអាយុ១៨ឆ្នាំឡើង ដែលត្រូវធ្វើសមាហរណកម្មទៅរស់នៅក្នុងគ្រួសារ និងសហគមន៍ ក្នុងម្នាក់ទទួលបានរបបគោលនយោបាយ ១.០៨០.០០០៛ (មួយលានប្រាំបីម៉ឺនរៀល)<br>- កុមារកំព្រាដែលស្នាក់នៅក្នុងមណ្ឌលថែទាំរបស់រដ្ឋទទួលបានប្រាក់ឧបត្ថម្ភសម្រាប់សម្លៀកបំពាក់ សម្ភារជំណេក អនាម័យ និងព្យាបាលជំងឺ ក្នុងមួយនាក់ទទួលបាន ១២០.០០០៛ (ដប់ពីរម៉ឺនរៀល) ១ដង ក្នុង១ឆ្នាំ<br>- ទារក កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ (HIV/DIDS) ដែលស្នាក់នៅមណ្ឌលថែទាំរបស់រដ្ឋ ក្នុងមួយនាក់ទទួលបានប្រាក់ឧបត្ថម្ភ ២០.០០០៛ (ពីរម៉ឺនរៀល) ក្នុងមួយខែ សម្រាប់បំប៉នសុខភាព<br>- ទារក កុមារអាយុ៥ឆ្នាំចុះទទួលមរណភាព ទទួលបានប្រាក់ឧបត្ថម្ភ រៀបចំបុណ្យសព ចំនួន ២៧០.០០០៛ (ម្ភៃប្រាំពីរម៉ឺនរៀល) ១ដងគត់ |

| | |
|---|---|
| | កុមារអាយុ ៥ឆ្នាំឡើងទទួលមរណភាព ទទួលបានប្រាក់ឧបត្ថម្ភ រៀបចំបុណ្យសព ចំនួន ៥៤០.០០០៛ (ហាសិបបួនម៉ឺនរៀល) ១ដងគត់<br>**ចំពោះករណីការអនុវត្តគម្រោងកម្មវិធីថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូ**<br>*កុមារដែលរស់នៅក្នុងមណ្ឌលថែទាំរបស់អង្គការមិនមែនរដ្ឋាភិបាល គឺត្រូវអនុលោមតាមគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌលថែទាំ និងអនុឡោមតាមស្មារតីនៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ និងអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ។*<br>*ការអនុវត្តគម្រោងកម្មវិធីថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាលគឺត្រូវអនុលោមតាមគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ ប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិនិងឪពុកម្តាយធម៌។* |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ***កុមារក្នុងមណ្ឌលថែទាំ (កុមាររស់នៅក្នុងមណ្ឌលរដ្ឋ ស្ថិតក្រោមក្រសួងស.អ.យ)***<br>១. ទម្រង់គ្រប់គ្រងករណីរបស់កុមារមានការចុះហត្ថលេខាពីអាជ្ញាធរមូលដ្ឋាន<br>២. សេចក្តីប្រកាសជូនដំណឹងជាសាធារណៈពីការស្វែងរកឪពុកម្តាយរបស់កុមារ<br>៣. អត្រានុកូលដ្ឋាន ឬលិខិតបញ្ជាក់កំណើតរបស់កុមារ<br>៤. ពាក្យស្នើសុំបញ្ចូលរបស់អ្នកនាំកុមារ ឬអ្នកកាន់ករណី /ពាក្យស្នើសុំបញ្ចូលកុមាររបស់មន្ទីរស.អ.យ.រាជធានី ខេត្ត ឬមជ្ឈមណ្ឌលទារក និងកុមារជាតិ<br>៥. ប្រវត្តិរូបសង្ខេបរបស់កុមារ<br>៦. លិខិតស្នើសុំបញ្ចូលកុមាររបស់មជ្ឈមណ្ឌលទារក និងកុមារជាតិ<br>៧. គោលការណ៍ស្នើសុំបញ្ចូលកុមាររបស់នាយកដ្ឋានកិច្ចការពារកុមារដើម្បីទទួលរបបគោលនយោបាយរបស់រដ្ឋ ពីឯកឧត្តមរដ្ឋមន្ត្រី<br>៨. ប្រកាសស្តីពីការបញ្ចូលកុមារទៅក្នុងមជ្ឈមណ្ឌលទារក និងកុមារជាតិ<br>៩. តាមដានត្រួតពិនិត្យវាយតម្លៃ និងធ្វើរបាយការណ៍អំពីស្ថានភាពកុមារ<br>***កុមារក្នុងមជ្ឈមណ្ឌលថែទាំរបស់រដ្ឋ ស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត***<br>១០.ចំពោះករណី ឯកសារបញ្ចូល ឬបញ្ចេញកុមាររបស់មជ្ឈមណ្ឌលថែទាំរដ្ឋ នៃរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុលោមតាមគោលការណ៍ណែនាំដែលក្រសួងស.អ.យ បានដាក់ចេញឱ្យអនុវត្ត។<br>***កុមារក្នុងមណ្ឌលថែទាំ របស់អង្គការមិនមែនរដ្ឋាភិបាល***<br>១១.ទម្រង់គ្រប់គ្រងករណីរបស់កុមារមានការចុះហត្ថលេខាពីអាជ្ញាធរមូលដ្ឋាន ឬប្រព័ន្ធគ្រប់គ្រងករណីអូស្កា ឬប្រព័ន្ធគ្រប់គ្រងករណីព្រីមែរ៉ូ<br>១២.ពាក្យស្នើសុំបញ្ចូលរបស់អ្នកនាំកុមារ ឬអ្នកកាន់ករណី<br>១៣.សេចក្តីប្រកាសជូនដំណឹងជាសាធារណៈពីការស្វែងរកឪពុកម្តាយរបស់កុមារ |

| | |
|---|---|
| | ១៤.អត្រានុកូលដ្ឋាន ឬលិខិតបញ្ជាក់កំណើតរបស់កុមារ<br>១៥.ប្រវត្តិរូបសង្ខេបរបស់កុមារ<br>១៦.សៀវភៅលឿងសម្រាប់គ្រប់គ្រងទិន្នន័យចេញ ឬចូល |
| **យោបល់** | កុមារកំព្រា កុមាររងគ្រោះ និងកុមារងាយរងគ្រោះ ដែលជាមុខសញ្ញាដែលត្រូវធានាឱ្យបាននូវឧត្តមប្រយោជន៍ និងសិទ្ធិជាមូលដ្ឋានរបស់ពួកគេ តាមរយៈការចូលរួមអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារមានរចនាសម្ព័ន្ធគ្រប់គ្រង តួនាទីភារកិច្ច និងមុខងារនៃអង្គភាពប្រតិបត្តិច្បាស់លាស់ ចូលរួមដោះស្រាយបញ្ហាសង្គម បង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ។ ជាមួយគ្នានេះត្រូវចូលរួមទប់ស្កាត់ការបោះបង់កុមារ និងការបំបែកកុមារចេញពីគ្រួសារ ដោយជំនួសមកវិញនូវការថែរក្សាកុមារនៅក្នុងគ្រួសារ ហើយមណ្ឌលថែទាំជាជម្រើសចុងក្រោយនិងបណ្តោះអាសន្ន។ |

## ៨.ការផ្តល់សេវាសុំកូនក្នុងប្រទេស

| ឈ្មោះសេវា | សេវាសុំកូនក្នុងប្រទេស |
|---|---|
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានកិច្ចការពារកុមារ<br>***ការិយាល័យកិច្ចការសុំកូនក្នុងប្រទេស***<br>លេខទូរស័ព្ទការិយាល័យ ០១៥ ៩៧៣ ៥៣៦ / ០១៧ ៤២៧ ២៥២<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>**❖ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត** |
| គោលបំណងនៃការផ្តល់សេវា | • សុំកូនគឺជាដំណោះស្រាយមួយដែលជួយឱ្យកុមារទទួលបានគ្រួសារមួយជាអចិន្ត្រៃយ៍ អាចទទួលបានផ្តល់ក្តីស្រឡាញ់ ភាពកក់ក្តៅ និងទទួលកេរ្តិ៍មរតក ពីគ្រួសារចិញ្ចឹមស្របច្បាប់ ដោយអនុលោមតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស ក្រមរដ្ឋប្បវេណី ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារក្នុងជំពូកទី៧ "ការធ្វើផែនការ អចិន្ត្រៃយ៍" សេចក្តីពន្យល់ស្តីពីសុំកូនក្នុងប្រទេស សៀវភៅណែនាំស្តីពីការអនុវត្តសុំកូនក្នុងប្រទេស និងគោលការណ៍ណែនាំសម្រាប់ការថែទាំជំនួសចំពោះកុមាររបស់អង្គការសហប្រជាជាតិ។<br>• កុមារទទួលបានការចិញ្ចឹមក្នុងគ្រួសារមួយជាអចិន្ត្រៃយ៍ដោយឪពុកម្តាយបង្កើតរបស់កុមារផ្ទេរសិទ្ធិ និងភារកិច្ចទទួលខុសត្រូវទាំងអស់ជូនឪពុកម្តាយចិញ្ចឹម ហើយកុមារនោះទទួលបានសិទ្ធិ និងកាតព្វកិច្ចនានា ដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ។<br>• កុមារទទួលបានការសុំកូនពេញលេញ ឬធម្មតា តាមរយៈសេចក្តីសម្រេចពីតុលាការ។ |

| | |
|---|---|
| មូលដ្ឋានគតិយុត្ត | ស្មុំកូនក្នុងប្រទេសប្រព្រឹត្តទៅបានដោយផ្អែកតាមច្បាប់ គោលនយោបាយ និងឯកសារពាក់ព័ន្ធដូចខាងក្រោម៖<br>- ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី (ឆ្នាំ២០០៦)<br>- ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស (ឆ្នាំ២០០៩)<br>- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ឆ្នាំ២០១០)<br>- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (ឆ្នាំ២០១០)<br>- ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧)<br>- អនុសញ្ញាស្តីពីសិទ្ធិកុមារ<br>- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ (ឆ្នាំ២០០៦)<br>- គោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩<br>- សេចក្តីពន្យល់អំពីស្មុំកូនក្នុងប្រទេស (ឆ្នាំ២០១៥)<br>- ប្រកាសស្តីពីនីតិវិធីក្នុងការអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ (ឆ្នាំ២០១១)<br>- ប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ (២០២១)<br>- សេចក្តីណែនាំស្តីពីទម្រង់បែបបទ និងគំរូលិខិតបទដ្ឋានសម្រាប់អនុវត្តប្រកាស ស្តីពីនីតិវិធីក្នុងការអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ (ឆ្នាំ២០១៣)<br>- ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តស្មុំកូនក្នុងប្រទេស (ឆ្នាំ២០២៣) |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | កុមារដែលអាចជាកម្មវត្ថុសម្រាប់ស្មុំកូនក្នុងប្រទេសត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖<br>• ជាគោលការណ៍កុមារត្រូវមានអាយុតិចជាង៨ឆ្នាំ សម្រាប់ស្មុំកូនពេញលេញ។ ដោយឡែកស្មុំកូនធម្មតាមិនកំណត់អាយុកូនសុំទេ ប៉ុន្តែកូនសុំមិនអាចមានអាយុច្រើនជាង ឬជាបុព្វញាតិរបស់អ្នកសុំបានទេ។<br>• កុមារដែលត្រូវបានប្រកាសថាជាកម្មវត្ថុស្មុំកូន ក្រោយពីកិច្ចខិតខំប្រឹងប្រែងរក្សាកុមារក្នុងគ្រួសារបង្កើតមិនទទួលជោគជ័យ។<br>• កុមារដែលត្រូវបានគេបោះបង់ចោល ឬបែកចេញពីគ្រួសារ ហើយអាជ្ញាធរមានសមត្ថកិច្ចរកមិនឃើញគ្រួសារ ឬសាច់ញាតិ (សូម្បីតែសមាជិកគ្រួសារផ្សេងទៀតកំពុងរស់នៅក្រៅប្រទេសកម្ពុជាក៏ដោយ) ក្រោយពីរកអស់លទ្ធភាពរយៈពេល៥(ប្រាំ) ខែជាប់ៗគ្នា។<br>• កុមារដែលឪពុកម្តាយបង្កើត ឬឪពុក ឬម្តាយនៅរស់ ហើយបានផ្តល់ការយល់ព្រមដោយស្ម័គ្រចិត្តចំពោះស្មុំកូនក្រោយទទួលបានការប្រឹក្សាយោបល់ពីភ្នាក់ងារសង្គមកិច្ច។<br>• កុមារកំព្រាឪពុកម្តាយ ហើយពុំមានសាច់ញាតិទទួលកុមារយកទៅចិញ្ចឹម។<br><br>**លក្ខណៈសម្បត្តិរបស់អ្នកសុំ៖**<br>**<u>ស្មុំកូនធម្មតា</u>** |

| | |
|---|---|
| | • **អាយុ៖** អ្នកដាក់ពាក្យសុំត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំឡើង។<br>• **ស្ថានភាពអាពាហ៍ពិពាហ៍៖** នៅលីវ ឬរៀបការរួច ប៉ុន្តែត្រូវមានការយល់ព្រមពីប្តី ឬប្រពន្ធរបស់ខ្លួន ក្នុងករណី អ្នកសុំមានសហព័ទ្ធ(លើកលែងតែប្តី ឬប្រពន្ធនោះ គឺជាឪពុក ឬម្តាយបង្កើតរបស់កូនស្មុំនោះ)។<br><u>**ស្មុំកូនពេញលេញ**</u><br>• **អាពាហ៍ពិពាហ៍៖** ជាបុគ្គលដែលមានសហព័ទ្ធ (ប្តីប្រពន្ធបានចុះសំបុត្រអាពាហ៍ពិពាហ៍)។ ប្តី ឬប្រពន្ធតែម្ខាងមិនអាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាង ទៀតមិនក្លាយជាម្តាយ ឬឪពុកចិញ្ចឹម (លើកលែងតែករណីដែលសហព័ទ្ធម្ខាងទៀតជាឪពុក ឬម្តាយបង្កើតរបស់កុមារ ដែលប្តី ឬប្រពន្ធរបស់គាត់កំពុងសុំកុមារជាកូនចិញ្ចឹម)។<br>**អាយុអប្បបរមា៖** ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុ យ៉ាងតិច ២៥ឆ្នាំ និងមានអាយុច្រើនជាងកូនសុំចាប់ពី ២០ឆ្នាំ ឡើងទៅ (យោងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)។<br>ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ឪពុកម្តាយចិញ្ចឹមត្រូវមានលក្ខណៈវិនិច្ឆ័យបន្ថែមដូចខាងក្រោម៖<br>- មានសមត្ថភាពក្នុងការគាំទ្រកុមារ<br>- មានសិលធម៌ និងសុជីវធម៌ល្អក្នុងការរស់នៅ<br>- មិនធ្លាប់ប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈឹម<br>- មានសុខភាពល្អផ្នែករាងកាយ និងស្មារតីក្នុងការថែទាំកូនៗ<br>- មានទំនាក់ទំនងល្អនៅក្នុងគ្រួសារ<br>- យល់ដឹងពីសិទ្ធិ និងកិច្ចការពារកុមារ<br>- មានស្ថិរភាពនៃចំណងអាពាហ៍ពិពាហ៍<br>- ភាពពេញចិត្ត និងការឯកភាពពីសមាជិកគ្រួសារ និងសាច់ញាតិអំពីស្មុំកូន<br>**ចំណាំ៖** សម្រាប់ជនជាតិបរទេសដែលមានលំនៅឋានអចិន្ត្រៃយ៍ក្រៅប្រទេសកម្ពុជា ហើយមានបំណងសុំកុមារកម្ពុជាដែលមានលំនៅឋានអចិន្ត្រៃយ៍នៅកម្ពុជាយកទៅចិញ្ចឹម ត្រូវអនុវត្តតាមច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស (ឆ្នាំ២០០៩)។ |
| ស្តង់ដារសេវា | ការអនុវត្តស្មុំកូនក្នុងប្រទេស មិនត្រូវគិតថ្លៃទេ លើកលែងថវិកាបង់ប្រដាប់ក្តីនៅតុលាការ។<br>ដំណើរការស្មុំកូនក្នុងប្រទេស មានជំហានដូចខាងក្រោម៖<br>**ជំហានទី១៖** ការដាក់ពាក្យ និងការពិនិត្យពាក្យសុំ<br>**ជំហានទី២៖** ការចុះប៉ាន់ប្រមាណអ្នកសុំដល់លំនៅឋាន<br>**ជំហានទី៣៖** ការផ្គូផ្គងរវាងកុមារដែលជាកម្មវត្ថុស្មុំ និងអ្នកសុំ<br>**ជំហានទី៤៖** ការត្រៀមកុមារ និងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម<br>**ជំហានទី៥៖** ការទុកដាក់កុមារសាកល្បង<br>**ជំហានទី៦៖** ការដាក់ពាក្យស្នើសុំដីកាសម្រេចពីតុលាការ<br>**ជំហានទី៧៖** ការទុកដាក់កុមារជាផ្លូវការជាមួយគ្រួសារចិញ្ចឹម |
| តម្រូវការឯកសារ | ១.ពាក្យស្នើសុំស្មុំកូនពេញលេញ ឬស្មុំកូនធម្មតា |

| | |
|---|---|
| ដើម្បីទទួលបានសេវា | ២.សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់អ្នកដាក់ពាក្យស្នើសុំ(សេចក្តីចម្លង ១ច្បាប់)<br>៣.សំបុត្រអាពាហ៍ពិពាហ៍ (សេចក្តីចម្លង ១ច្បាប់)<br>៤.របាយការណ៍វេជ្ជសាស្ត្រពីគ្រូពេទ្យដែលទទួលស្គាល់ត្រឹមត្រូវបញ្ជាក់ថាបេក្ខជនមាន សុខភាពរាងកាយ និងផ្លូវចិត្តល្អ<br>៤.ឯកសារដែលបញ្ជាក់ពី សញ្ជាតិ ទីលំនៅអចិន្ត្រៃយ៍ និងមុខងាររបស់គាត់ក្នុងប្រទេស កម្ពុជា (ឧ. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដោយមានបញ្ជាក់ថាថតចំលងតាមច្បាប់ដើម)<br>៥.ឯកសារបញ្ជាក់ថា គាត់អាចឧបត្ថម្ភគាំទ្រកុមារបាន ដូចជា លិខិតបញ្ជាក់ពីប្រាក់ចំណូល<br>៦.លិខិតថ្កោលទោសចេញដោយក្រសួងយុត្តិធម៌<br>៧.របាយការណ៍ស្តីពីការទុកដាក់កុមារក្នុងការថែទាំជំនួស<br>៨.សេចក្តីប្រកាសពីការបោះបង់ចោលកុមារ (ប្រសិនបើមាន)<br>៩.សេចក្តីប្រកាសស្វែងរកឪពុកម្តាយ ឬសាច់ញាតិ (ប្រសិនបើមាន)<br>១០.ទម្រង់សម្រេចបញ្ចូលកុមារក្នុងផែនការអចិន្ត្រៃយ៍<br>១១.ឯកសារបញ្ជាក់អំពីការយល់ព្រមរបស់ឪពុកម្តាយបង្កើតអំពីសុំកូន(ប្រសិនបើ មាន)<br>១២.របាយការណ៍ស្តីពីការសិក្សាវាយតម្លៃដល់លំនៅដ្ឋានរបស់អ្នកសុំ<br>១៣.របាយការណ៍ស្តីពីការសិក្សាអំពីឧត្តមប្រយោជន៍របស់កុមារ<br>១៤.ទម្រង់ផ្គូផ្គងកុមារដែលជាកូនសុំជាមួយគ្រួសារសុំ<br>១៥.ប្រវត្តិរូបកុមារ និងសំបុត្រកំណើតកុមារ ។ល។<br>១៦.លិខិតធានាអះអាងចំពោះការប្តេជ្ញាចិត្តលើការចិញ្ចឹមបីបាច់កូនសុំ<br>១៧.ឯកសារផ្សេងៗទៀតតាមការចាំបាច់ |
| យោបល់ | មុនពេលពិចារណាលើសុំកូនក្នុងប្រទេស មន្ត្រីសង្គមកិច្ច បុគ្គលិកសង្គម និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវលើកកម្ពស់គោលការណ៍ទប់ស្កាត់កុមារបែកចេញពីគ្រួសារ ការពង្រឹង និងការរក្សាកុមារក្នុងគ្រួសារ ដែលជាមូលដ្ឋានគ្រឹះនៃការអនុវត្តកិច្ចការពារកុមារ។ មុននឹងដំណើរការសុំកូនក្នុងប្រទេស ភ្នាក់ងារសង្គមកិច្ច មន្ត្រីសង្គមកិច្ច បុគ្គលិកសង្គម អាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖<br>- ត្រូវមានឯកសារគ្រប់គ្រាន់បញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់សេវារក្សាកុមារក្នុង គ្រួសារ និងសេវាបង្រួបបង្រួមគ្រួសារដែលបានធ្វើកន្លងមក និងបញ្ជាក់ពីមូលហេតុនៃការ សម្រេចបញ្ចូលករណីកុមារជាកម្មវត្ថុសុំកូន។<br>- ការសម្រេចចិត្តចំពោះសុំកូនក្នុងប្រទេសត្រូវធ្វើឡើងដោយមានការចូលរួម និងការយល់ព្រម ពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារ និងកុមារ (ក្នុងករណីកុមារដឹងក្តី)។<br>- ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាណាតែផុតរយៈពេល ៩០ (កៅសិប) ថ្ងៃនៃ ថ្ងៃធ្វើការ បន្ទាប់ពីឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់កុមារបានផ្តល់ការយល់ ព្រមចំពោះសុំកូន។<br>- មិនគួរបំបែកកុមារដែលជាបងប្អូនបង្កើតឡើយ លើកលែងតែការបំបែកនេះធ្វើឡើងដើម្បី ឧត្តមប្រយោជន៍របស់កុមារ។ |

| | |
|---|---|
| | - ត្រូវសិក្សាពីឧត្តមប្រយោជន៍របស់កុមារ ដោយសិក្សាពីផលវិជ្ជមាន និងអវិជ្ជមាន ដែលអាចមានឥទ្ធិពលដល់កុមារជាលទ្ធផលនៃស្មុំកូន។<br>- ឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារត្រូវទទួលបានការពិគ្រោះយោបល់អំពីសេវារក្សាកុមារក្នុងគ្រួសារ និងអំពីផលវិបាក នៃការសម្រេចចិត្តលាលែងពីអ្នកមានអំណាចមេបា និងការផ្តល់ការយល់ព្រមលើស្មុំកូន។ |

## ៩. ការផ្តល់សេវាដល់មនុស្សវ័យចាស់សកម្មតាមសមាគម

| ឈ្មោះសេវា | សេវាបច្ចេកទេសជួយដល់សមាគមមនុស្សវ័យចាស់អន្តរជំនាន់ និងពហុមុខងារ |
|---|---|
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានមនុស្សចាស់និងអតីតយុទ្ធជន<br>ការិយាល័យបណ្តុះបណ្តាលនិងអភិវឌ្ឍន៍គំរូថែទាំមនុស្សចាស់<br>ទូរស័ព្ទ ៖ ០៦៩ ៣៦០ ០០០<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មន្ទីរស.អ.យ. ទាំង២៥ រាជធានី ខេត្ត<br>❖ រដ្ឋបាលឃុំ សង្កាត់ |
| គោលបំណង នៃការផ្តល់សេវា | • អភិវឌ្ឍសមាគមមនុស្សចាស់អន្តរជំនាន់ដើម្បីធ្វើការជាមួយមនុស្សវ័យចាស់ និងសមាជិកសមាគម ជួយឱ្យពួកគាត់មានភាពសកម្ម បង្កលក្ខណៈប្រសើរឡើងនូវសុខុមាលភាព ជីវភាព ការទទួលបានសេវាសង្គម ការយកចិត្តទុកដាក់ និងការជួយគ្នាក្នុងសមាគម<br>• បណ្តុះបណ្តាលជំនាញបឋមដល់មនុស្សវ័យចាស់សកម្មឱ្យមានសមត្ថភាព និងលទ្ធភាពប្រកបរបររកស៊ីចិញ្ចឹមជីវិតដោយថ្លៃថ្នូរសមរម្យ។ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ប្រកាសលេខ ២៩០ ស.អ.យ. ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននិងអង្គភាពក្រោមឱវាទនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>• គោលការណ៍ការណែនាំស្តីពីការបង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩<br>• គោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧<br>• ផែនការសកម្មភាព ២០១៨-២០២០ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ |

| | |
|---|---|
| | • ផែនការសកម្មភាព ២០២១-២០២៥ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | មនុស្សវ័យចាស់ ចាប់ពីអាយុ ៦០ឆ្នាំឡើងទៅ |
| ស្តង់ដារសេវា | ការថែទាំសុខភាពបឋម ៖ ការវាស់សម្ពាធឈាម ថ្លឹងទម្ងន់ វាស់កម្ពស់ ហាត់ប្រាណ -ល-<br>ការថែទាំខ្លួនឯង ៖ បង្ហាត់ដោយបុគ្គលិកជំនាញ ឱ្យពួកគាត់ចេះថែទាំខ្លួនឯង<br>ការលើកកម្ពស់ជីវភាព ៖ ការរកប្រាក់ចំណូល តាមរយៈការធ្វើកសិកម្ម និងសិប្បកម្មខ្នាតតូច<br>ការផ្តល់ការថែទាំនិងគាំទ្រសង្គម ៖ សិល្បៈ វប្បធម៌ និងព័ត៌មាននានា |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | មិនតម្រូវឱ្យមានឯកសារ |
| យោបល់ | -ចុះឈ្មោះចូលជាសមាជិកសមាគមមនុស្សវ័យចាស់ដែលនៅជិតពួកគាត់<br>-រាល់សមាជិកទាំងអស់ត្រូវបង់ភាគទានទៅតាមលក្ខន្តិកៈរបស់សមាគម |

## ១០.ការផ្តល់ជំនួយលើការស្វែងរកសេវាសង្គមសម្រាប់គ្រួសារ

| | |
|---|---|
| ឈ្មោះសេវា | ការប្រឹក្សាយោបល់ដើម្បីដោះស្រាយបញ្ហាដល់គ្រួសារ និងសម្របសម្រួលជួបជាមួយអ្នកជំនាញទៅតាមតម្រូវការជាក់ស្តែង |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច<br>❖ នាយកដ្ឋានកិច្ចការគ្រួសារ<br>ការិយាល័យផ្តល់សេវាគាំទ្រគ្រួសារនិងប្រឹក្សាយោបល់<br>ទូរស័ព្ទការិយាល័យ ៖ ០៦៦ ៥១៧ ៥១៧ / ០១២ ៦៨ ៣៦ ៦៥<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មន្ទីរ ស.អ.យ. រាជធានី ខេត្ត<br>❖ ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមទូទាំងប្រទេស |
| គោលបំណងនៃការផ្តល់សេវា | កម្មវិធីផ្តល់សេវាគាំទ្រគ្រួសារ និងសេវាប្រឹក្សាយោបល់ដល់គ្រួសារ ឬបុគ្គល ជាសេវាកម្មសាធារណៈរបស់ក្រសួង ស.អ.យ. ត្រូវបានបង្កើតឡើងក្នុងគោលបំណង ជួយបង្កើនសុខដុមមនាក្នុងក្រុមគ្រួសាររបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានទូទាំង២៥រាជធានី ខេត្ត ដោយជួយគាំទ្រឱ្យសមាជិកនៅក្នុងគ្រួសារទទួលបានព័ត៌មានជាក់លាក់ពីការដោះស្រាយបញ្ហា ឬវិបត្តិនានាដែលមាននៅក្នុងក្រុមគ្រួសារ។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសលេខ២៩០ស.អ.យ. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច |

| | |
|---|---|
| អតិថិជនដែលមានសិទ្ធិទទួលសេវា | សមាជិកនីមួយៗក្នុងក្រុមគ្រួសារ ជាពិសេសមេគ្រួសារ និងជនដែលជាគោលជំហរក្នុងគ្រួសារ |
| ស្តង់ដារសេវា | អតិថិជននឹងទទួលបានសេវាប្រឹក្សាយោបល់និងព័ត៌មានដោយមិនអស់កម្រៃជាមួយមន្ត្រីសង្គមកិច្ច និងការសម្របសម្រួលដើម្បីបញ្ជូនអតិថិជនទៅជួបជាមួយបុគ្គលិកជំនាញរបស់អង្គការដៃគូ ឬក្រុមហ៊ុន នានា ដែលមានផ្តល់សេវានានាដើម្បីដោះស្រាយបញ្ហាគ្រួសារដូចជាការស្តារសម្បទាផ្លូវចិត្ត ការគិតវិជ្ជមាន ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការលែងលះ ការផ្តល់សក្ខីកម្មនៅតុលាការ បង្រួបបង្រួមកុមារទៅក្នុងគ្រួសារ ការសមាហរណកម្មជនរងគ្រោះនិងងាយរងគ្រោះទៅក្នុងគ្រួសារ ឬការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ។ល។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់កំណើត |
| យោបល់ | គ្រួសារមានសុភមង្គល ឬបុគ្គលមានសុខភាពផ្លូវចិត្តល្អឬសន្តិភាពផ្លូវចិត្ត ដើម្បីជាកម្លាំងចលករចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គមជាតិ និងនាំឱ្យសង្គមមានសណ្តាប់ធ្នាប់សាធារណៈ សង្គមមានសន្តិសុខ និងសុខសុវត្ថិភាព។ |

## ផ្នែកទី២. អគ្គនាយកដ្ឋានស្តារសម្បទា

### ១១. ការជួយអន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនមានពិការភាព

| ឈ្មោះសេវា | អន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនមានពិការភាព |
|---|---|
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានស្តារសម្បទា<br>❖ រដ្ឋបាលសិទ្ធិជនពិការ នៃនាយកដ្ឋានសុខុមាលភាពជនពិការ<br>លេខទូរស័ព្ទ ០១២ ៨៤៨ ១២៤ /០១០ ៩៦៧ ៥៨៦ /០១១ ៩៩៥ ៥៤៥<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |
| គោលបំណងនៃការផ្តល់សេវា | ទទួលពាក្យបណ្តឹងពីជនពិការ និងអង្គភាព<br>• ចុះអន្តរាគមន៍ភ្លាមៗ<br>• ប្រតិកម្មឆាប់រហ័សឆ្លើយតបនឹងបណ្តាញទំនាក់ទំនងសង្គមនានា រឿងរំលោភសិទ្ធិជនពិការ<br>• ចុះប្រមូលព័ត៌មានទាក់ទងនឹងករណីរំលោភសិទ្ធិជនពិការ<br>• ធ្វើអធិការកិច្ចចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនពិការ ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ ផ្នែកឯកជន ព្រមទាំងអង្គការពាក់ព័ន្ធនានា<br>• ផ្តល់សេវាសម្របសម្រួល ផ្សះផ្សា ជួយដោះស្រាយនូវវិវាទផ្សេងៗ ដែលកើតឡើងក្នុងក្របខណ្ឌនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• កសាងសំណុំរឿងប្តឹងទៅតុលាការ ចំពោះអ្នកប្រព្រឹត្តបទល្មើស និងបទបញ្ញត្តិនៃច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• អនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ<br>• ប្រកាសលេខ ០៥៦ ស.អ.យ. ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្តីពីការបង្កើតរដ្ឋបាលសិទ្ធិជនពិការ<br>• សារាចរណែនាំលេខ០០៥ ស.អ.យ./សរណន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការសម្របសម្រួលសមស្របសម្រាប់ការងាររបស់ជនពិការ<br>• ប្រកាសអន្តរក្រសួងលេខ ២៤៨ ស.អ.យ.ប្រក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព |

| | |
|---|---|
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ក្រសួងស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលជាប្រធានអង្គភាព ម្ចាស់អាជីវកម្ម អង្គការ និងនាយកក្រុមហ៊ុន ព្រមទាំងជនពិការ |
| ស្តង់ដារសេវា | ១. មានរយៈពេល៖ ជាក់ស្តែងតាមករណី<br>២. តម្លៃសេវា៖ ឥតគិតថ្លៃ<br>៣. សុពលភាព៖ ពុំមានកាលបរិច្ឆេទទេ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១. ប្រវត្តិរូបសង្ខេបអតិថិជន<br>២. ទឡ្ហីករណ៍ដែលអតិថិជនមាន<br>៣. តម្រូវការឯកសារពាក់ព័ន្ធមួយចំនួន |
| យោបល់ | |

## ១២. ការផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនមានពិការភាព

| | |
|---|---|
| ឈ្មោះសេវា | សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនមានពិការភាព |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានស្តារសម្បទា<br>❖ នាយកដ្ឋានសុខុមាលភាពជនពិការ<br>ទូរស័ព្ទ ៖ ០១៦ ៥៥៩ ៩១៧<br>ការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈមុខរបរ និងការងារ<br>ទូរស័ព្ទ ៖ ០១២ ៣៣៩ ៥៤៣<br>អ៊ីមែល ៖ ratanacamswk@gmail.com<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ សាលា JCIA ភូមិឆ្លូក សង្កាត់គោកកោ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ<br>ទូរសព្ទ ៖ ០១៦ ៦៦៨ ៣៤៩ |
| គោលបំណងនៃការផ្តល់សេវា | កសាងសមត្ថភាពជនពិការតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើបទដ្ឋានរួមមួយសម្រាប់មជ្ឈមណ្ឌលនិងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការទាំងអស់ដែលជាបទដ្ឋានពង្រឹងគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងមុខរបរ |
| មូលដ្ឋានគតិយុត្ត | សារាចរណែនាំលេខ ០០១ ស.អ.យ. ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការពង្រឹងគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនពិការដែលមកទទួលសេវាបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ |
| ស្តង់ដារសេវា | **គ្រប់មជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ៖**<br>កម្រិតបទដ្ឋានអប្បបរមា ១៤ចំណុច ដើម្បីធានាគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ៖ |

១. មានអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

២. អនុវត្តនូវបទដ្ឋានគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ

៣. សិក្សាពីទីផ្សារកម្លាំងពលកម្ម ដើម្បីកំណត់មុខជំនាញសម្រាប់បណ្តុះបណ្តាល

៤. ផ្តល់សេវាកម្មប្រឹក្សាយោបល់ជាមួយសិក្ខាកាមលើការណែនាំតម្រង់ទិសសម្រាប់ជំនួយក្នុងការជ្រើសរើសមុខជំនាញ និងការងារសមស្រប

៥. ផ្តល់ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈសមស្របទៅនឹងតម្រូវការទីផ្សារការងារ និងមុខរបរ

៦. គ្រូបណ្តុះបណ្តាលត្រូវមានសមត្ថភាព និងគរុកោសល្យគ្រប់គ្រាន់ក្នុងការអនុវត្តកម្មវិធីសិក្សា

៧. ត្រូវធ្វើបច្ចុប្បន្នកម្មលើកម្មវិធីសិក្សាឱ្យស្របនឹងតម្រូវការទីផ្សារ

៨. ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងស្មារតីចំពោះសិក្ខាកាមទាំងពេលសិក្សា និងប្រកបការងារ

៩. ផ្តល់ការបំប៉នជំនាញបន្ថែមដើម្បីអភិវឌ្ឍសមត្ថភាព និងឱកាសថ្មីៗសម្រាប់សិស្សដែលកំពុងប្រកបការងារ

១០. ត្រូវមានបទបញ្ជាផ្ទៃក្នុងដែលធានាដល់ការអនុវត្តកម្មវិធីសិក្សា ដើម្បីទទួលបានជោគជ័យ

១១. ត្រូវមានកម្មវិធីបណ្តុះបណ្តាលបន្ថែមនូវជំនាញគួបផ្សំ និងបង្កឱកាសឱ្យសិក្ខាកាមបានចូលរួមក្នុងសកម្មភាពនានារបស់សង្គម

១២. ផ្តល់ និងសម្របសម្រួលដើម្បីទទួលបានកម្ចីគ្មានការប្រាក់ ឬមានការប្រាក់ទាប ផ្តល់ជាជំនួយ និងឧបករណ៍ផ្សេងៗដើម្បីជួយដល់ជនពិការមានលទ្ធភាពបង្កើតមុខរបរផ្ទាល់ខ្លួន និងជួយសម្របសម្រួលក្នុងការស្វែងរកការងារ

១៣. ត្រូវមានកម្មវិធីការងារតាមដានសិស្សបញ្ចប់វគ្គ ដើម្បីគាំទ្រឱ្យមាននិរន្តរភាពមុខរបរ

១៤. ហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលត្រូវសម្រួលដល់លទ្ធភាពចល័តចេញចូលរបស់ជនពិការគ្រប់ប្រភេទ

**លក្ខណៈវិនិច្ឆ័យ ៧ ចំណុច៖**

១. រយៈពេលសមស្របសម្រាប់ការបណ្តុះបណ្តាល

២. គ្រូបណ្តុះបណ្តាលត្រូវមានលក្ខណសម្បត្តិ

ក.មានការទទួលស្គាល់សមត្ថភាពពីវិទ្យាស្ថាន ឬស្ថាប័នបណ្តុះបណ្តាលបច្ចេកទេសជាផ្លូវការ

ខ.មានជំនាញ និងបទពិសោធគ្រប់គ្រាន់ក្នុងការបង្រៀន

គ.មានគរុកោសល្យ ឬភាពប៉ិនប្រសប់ក្នុងការផ្ទេរចំណេះដឹងនិងជំនាញ

៣. កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងមុខវិជ្ជាចម្រុះបន្ថែម (អក្ខរកម្ម លេខនព្វន្ត ជំនួញ ចំណេះដឹងផ្នែកទីផ្សារ និងគោលការណ៍គ្រប់គ្រង....)

៤. ត្រូវធ្វើបច្ចុប្បន្នភាពលើកម្មវិធីបណ្តុះបណ្តាលទៅតាមតម្រូវការទីផ្សារ

៥. សម្ភារបណ្តុះបណ្តាលត្រូវផ្គត់ផ្គង់ទៅតាមតម្រូវការនៃវគ្គជំនាញនីមួយៗ

៦. ការងារបណ្តុះបណ្តាលត្រូវមានទ្រឹស្តីផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែង (៣០:៧០)

៧. ត្រូវផ្តល់សេវាគាំពារសុខភាពនិងសម្របសម្រួលដល់ការប្រើប្រាស់ ឧបករណ៍ជំនួយ (ក្នុងកំឡុងពេលសិក្សា)

**លក្ខណៈនៃបទដ្ឋានវិញ្ញាបនបត្រ ២២ ចំណុច ៖**

១. ចំពោះប្រភេទទីមួយ គឺប្រើសម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលចាប់ពី០៦ខែឡើងទៅហើយចុះហត្ថលេខាបញ្ជាក់នៅលើវិញ្ញាបនបត្រដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

២. ប្រភេទទីពីរ គឺប្រើសម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលតិចជាង ០៦ខែ ហើយចុះហត្ថលេខាបញ្ជាក់នៅលើវិញ្ញាបនបត្រដោយប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត

៣. ទម្រង់បទដ្ឋានវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវមានព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស មានទីតាំងខ្ពស់ជាងគេនៅចន្លោះក្បាលរចនា

៤. គំរូវិញ្ញាបនបត្រទាំងពីរត្រូវមានពណ៌ទឹកមាសជុំវិញក្រដាសជាក្បាច់រចនាបថខ្មែរ

៥. ទីតាំងនៃស្លាកសញ្ញារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការសាមីត្រូវមានទីតាំងកម្ពស់ស្មើគ្នា

៦. វិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រូវចុះហត្ថលេខាដោយនាយកប្រធានអង្គការសាមី

៧. ចំពោះវិញ្ញាបនបត្រដែលមានរយៈពេលបណ្តុះបណ្តាលវិជ្ជាជីវៈតិចជាង ០៦ខែ ត្រូវបោះពុម្ពលើផ្ទៃក្រដាសពណ៌ស

៨. ចំពោះវិញ្ញាបនបត្រដែលមានរយៈពេលបណ្តុះបណ្តាលវិជ្ជាជីវៈដែលចាប់ពី ០៦ខែឡើងទៅត្រូវបោះពុម្ពលើផ្ទៃក្រដាសពណ៌ពងមាន់

៩. គ្រប់វិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវមានកម្មវិធីបណ្តុះបណ្តាលនៅផ្នែកខាងខ្នងនៃវិញ្ញាបនបត្រ ដោយមានការចុះហត្ថលេខាបញ្ជាក់ពីនាយកសាលាបានឃើញ និងឯកភាពដោយប្រធានមណ្ឌល

១០. តួអក្សរខ្មែរស្តីពី ព្រះរាជាណាចក្រកម្ពុជាត្រូវប្រើពណ៌ខ្មៅ Limon R4 ទំហំ៣២ ជាតិ សាសនា ព្រះមហាក្សត្រ ត្រូវប្រើពណ៌ខ្មៅ Limon R4 ទំហំ៣១

១១. តួអក្សរខ្មែរស្តីពីវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវប្រើពណ៌ខ្មៅ Limon R5 ទំហំ៣៤

១២. តួអក្សរអង់គ្លេសស្តីពីវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវប្រើពណ៌ខ្មៅ Arial ទំហំ ១០

១៣. តួអក្សរអង់គ្លេសស្តីពីអង្គការស្ថាប័នបណ្តុះបណ្តាលត្រូវដាក់ពីក្រោមស្លាកសញ្ញាហើយមានទំហំសមរម្យ

១៤. តួអក្សរខ្មែរស្តីពីលេខត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២២

១៥. តួអក្សរអង់គ្លេសស្តីពីលេខត្រូវប្រើអក្សរពណ៌ខ្មៅ Arial ទំហំ១០

១៦.ចំពោះវិញ្ញាបនបត្រដែលត្រូវបញ្ជាក់ទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រើ Limon R4 ទំហំ ២៤

| | |
|---|---|
| | ១៧.ចំពោះវិញ្ញាបនបត្រដែលត្រូវបញ្ជាក់ទទួលស្គាល់ត្រឹមថ្នាក់ខេត្ត តួអក្សរខ្មែរស្តីពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវប្រើ Limon R4 ទំហំ ២៤<br>១៨. ចំពោះរូបថតរបស់សិក្ខាកាមត្រូវមានទំហំ ៤ x ៦ដាក់ចំកណ្តាលផ្នែកខាងក្រោម<br>១៩. តួអក្សរខ្មែរស្តីពីទម្រង់ខ្លឹមសារនៃវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២៤ ចំណែកឯតួអក្សរខ្មែរស្តីពីការបញ្ជាក់កិនភាគ និងលទ្ធផលសិក្សារបស់សិក្ខាកាមត្រូវប្រើអក្សរពណ៌ខ្មៅ Limon R4 ទំហំ ២៤<br>២០. តួអក្សរអង់គ្លេសស្តីពីទម្រង់ខ្លឹមសារនៃវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅArial ទំហំ ១០ ចំណែកឯតួអក្សរខ្មែរស្តីពីការបញ្ជាក់កិនភាគ និងលទ្ធផលសិក្សារបស់សិក្ខាកាមត្រូវប្រើអក្សរពណ៌ខ្មៅដិត Times New Roman ទំហំ ១២<br>២១. ចំពោះវិញ្ញាបនបត្រទាំងពីរប្រភេទតួអក្សរស្តីពី ថ្ងៃខែឆ្នាំ បានឃើញ និងឯកភាព ដែលត្រូវបញ្ជាក់លើវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២៤<br>២២. ចំពោះវិញ្ញាបនបត្រទាំងពីរប្រភេទតួអក្សរស្តីពី ឋានៈ តួនាទី នៃអ្នកដែលត្រូវបញ្ជាក់លើវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon R4 ទំហំ ២៤ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១. សំណើរបស់សាមីខ្លួនជនពិការ<br>២. សំណើរបស់ស្ថាប័ន និងអង្គការនានា<br>៣. ការសម្រេចរបស់ប្រធានមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ |
| យោបល់ | កម្រិតបទដ្ឋានរួមបានផ្តល់ឱ្យមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបំពេញបាននូវ ៖<br>- តម្រូវការជាមូលដ្ឋានរបស់ជនពិការ និងគ្រួសារមានភាពប្រសើរឡើងតាមរយៈកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសំដៅបង្កើនប្រាក់ចំណូលដោះស្រាយមុខរបរ និងរកការងារឱ្យជនពិការធ្វើ<br>- បង្កើនប្រភពចំណូលរបស់ជនពិការតាមរយៈកិច្ចប្រកបមុខរបរ និងបម្រើការងារ<br>- បង្កើនសមត្ថភាពជំនាញ និងចំណេះដឹងរបស់ជនពិការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារនិងក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់ជនពិការ<br>- ការកែលម្អគុណភាពវគ្គបណ្តុះបណ្តាលឱ្យឆ្លើយតបទៅនឹងទីផ្សារការងារ<br>- បង្កើត និងជំរុញយន្តការអនុវត្តបទដ្ឋានឱ្យមានផែនការច្បាស់លាស់។ |

## ១៣.ការផ្តល់សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនមានពិការភាព

| | |
|---|---|
| ឈ្មោះសេវា | សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនមានពិការភាព |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានស្តារសម្បទា<br>❖ រដ្ឋបាលសិទ្ធិជនពិការ នៃនាយកដ្ឋានសុខុមាលភាពជនពិការ |

| | |
|---|---|
| | ទូរស័ព្ទ ៖ ០១១ ៩៩៥ ៥៤៥ និង ០១២ ៨៤៨ ១២៤ ឬ ០១៦ ៥៥៩ ៩១៧<br>អ៊ីមែល ៖ ratanacamswk@gmail.com<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |
| គោលបំណង នៃការផ្ដល់សេវា | • ការពារសិទ្ធិ និងសេរីភាពរបស់ជនពិការ<br>• ការពារផលប្រយោជន៍ជនពិការ<br>• ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• អនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្ដីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ<br>• ប្រកាសលេខ ០៥៦ ស.អ.យ. ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្ដីពីការបង្កើតរដ្ឋបាលសិទ្ធិជនពិការ<br>• សារាចរណែនាំលេខ០០៥ ស.អ.យ./សរណន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ស្ដីពីការសម្របសម្រួលសមស្របសម្រាប់ការងាររបស់ជនពិការ<br>• ប្រកាសអន្តរក្រសួងលេខ ២៤៨ ស.អ.យ.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព<br>• ប្រកាសអន្តរក្រសួងលេខ ៩៥៩ ស.អ.យ. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់នូវឯកសារណែនាំគោលស្ដីពីនីតិវិធីអធិការកិច្ចលើវិស័យពិការភាពនៃព្រះរាជាណាចក្រកម្ពុជា |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលជាប្រធានអង្គភាព ម្ចាស់អាជីវកម្ម អង្គការនិងនាយកក្រុមហ៊ុន ព្រមទាំងជនពិការ |
| ស្តង់ដារសេវា | • មានរយៈពេល៖ ៣០ថ្ងៃ<br>• តម្លៃសេវា៖ ឥតគិតថ្លៃ<br>• សុពលភាព៖ ០១ឆ្នាំ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ឯកសារសេវាចុះបញ្ជិកា៖<br>១.លិខិតមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>២. ពាក្យស្នើសុំចុះបញ្ជិកា<br>៣. ផែនការអនុវត្ត<br>៤. សេចក្ដីប្រកាសជូនដំណឹងស្ដីពីចំនួនកម្មករនិយោជិតពិការ<br>៥. សេចក្ដីប្រកាសពីប្រាក់ខែអប្បរមារបស់កម្មករ ( ទទួលស្គាល់ពីក្រសួងការងារ )<br>៦. គោលនយោបាយ/គោលការណ៍គោរពសិទ្ធិជនពិការក្នុងស្ថាប័ន<br>៧. កាតាឡុកការបង្កលក្ខណៈងាយស្រួលដល់ជនពិការ ( ACCESSIBLE CATALOG )<br>៨. ពាក្យស្នើសុំបង់ភាគទាន |

| | |
|---|---|
| | ៩. ប្រវត្តិរូបជនពិការ |
| យោបល់ | |

## ១៤. ការផ្តល់របបឧបត្ថម្ភគោលនយោបាយចំពោះជនមានពិការភាពនៅតាមសហគមន៍

| ឈ្មោះសេវា | របបគោលនយោបាយឧបត្ថម្ភចំពោះជនពិការក្រីក្រនៅតាមសហគមន៍ |
|---|---|
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ គណៈកម្មការសម្របសម្រួល និងជំរុញការអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ និងអនុគណៈកម្មការ<br>❖ អគ្គនាយកដ្ឋានស្តារសម្បទា<br>❖ នាយកដ្ឋានសុខុមាលភាពជនពិការ<br>ការិយាល័យស្តារលទ្ធភាពពលកម្ម<br>លេខទូរស័ព្ទ៖ ០១២ ៥៦០ ៨៤៩<br>អាសយដ្ឋាន៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មូលនិធិជនពិការ<br>លេខទូរស័ព្ទ៖ ០១៧ ៤៤៧ ២៤១ /០៨៩ ៦៧៨ ៨០៥<br>អាសយដ្ឋាន៖ ផ្លូវជាតិលេខ៦អា សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ<br>❖ គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ រាជធានី ខេត្ត (លេខាធិការដ្ឋានមន្ទីរ ស.អ.យ. រាជធានី ខេត្ត)<br>❖ អនុគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ក្រុង ស្រុក ខណ្ឌ<br>❖ ក្រុមការងារឃុំ សង្កាត់ |
| គោលបំណងនៃការ ផ្តល់សេវា | • អនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• រួមចំណែកអនុវត្តយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិនានាដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ<br>• ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនពិការក្រីក្រនៅតាមសហគមន៍<br>• ស្តារលទ្ធភាពពលកម្ម និងកសាងជីវភាពរស់នៅឡើងវិញដល់ជនពិការក្រីក្រនៅតាម សហគមន៍<br>• ទប់ស្កាត់ កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថានរបស់ជនពិការក្រីក្រនៅតាមសហគមន៍<br>• ផ្តល់សេវាសង្គមកិច្ចដល់ជនពិការក្រីក្រនៅតាមសហគមន៍ឱ្យមានប្រសិទ្ធភាព |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ |

| | |
|---|---|
| | • អនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃ២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ជនពិការមានពិការភាពធ្ងន់ធ្ងរ ក្រីក្របំផុតនិងគ្មានទីពឹង<br>• ជនពិការចាស់ជរា ក្រីក្របំផុតនិងគ្មានទីពឹង<br>• ជនពិការមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្រីក្របំផុតគ្មានទីពឹង |
| ស្តង់ដារសេវា | ប្រាក់ឧបត្ថម្ភជីវភាពរស់នៅប្រចាំខែ ២០.០០០៛(ពីរម៉ឺនរៀល)ក្នុងមួយខែ សម្រាប់រយៈពេល ០៣ខែ ០៦ខែ និង ១២ខែ តាមរយៈការពិនិត្យ និងវាយតម្លៃពីគណៈកម្មការគ្រប់គ្រង របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ រាជធានី ខេត្ត<br>ទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម រួមមាន ៖<br>១. សេវាស្តារលទ្ធភាពពលកម្ម<br>២. ប្រាក់សម្រាប់អាហារក្នុងអំឡុងពេលទទួលសេវាស្តារលទ្ធភាពពលកម្ម ៣.០០០៛ (បីពាន់រៀល) ក្នុងមួយថ្ងៃ<br>៣. ប្រាក់សោហ៊ុយធ្វើដំណើរមកទទួលសេវាស្តារលទ្ធភាពពលកម្មទៅមក ១០.០០០៛ (មួយម៉ឺនរៀល)<br>៤. ប្រាក់ឧបត្ថម្ភទៅពិនិត្យ ព្យាបាល ថែទាំសុខភាព នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ៣០.០០០៛ (បីម៉ឺនរៀល)ម្នាក់ (មួយលើក/ឆ្នាំ) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១. ប័ណ្ណសមធម៌កម្រិតភាពក្រីក្រដែលចេញដោយក្រសួងផែនការ<br>២. មានលំនៅឋាន ឬកន្លែងស្នាក់នៅដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន<br>៣. ប្រកាសទទួលស្គាល់ជនពិការដើម្បីទទួលបានរបបគោលនយោបាយជនពិការក្រីក្រនៅតាមសហគមន៍ចេញដោយក្រសួង ស.អ.យ.<br>៤. ប័ណ្ណសង្គមកិច្ច ដែលចេញដោយគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍រាជធានី ខេត្ត តាមរយៈប្រកាសរបស់ក្រសួង ស.អ.យ.<br>៥.គណនីផ្ទាល់ខ្លួនរបស់ជនពិការនៅធនាគារអេស៊ីលីដា ដើម្បីផ្ទេរថវិការបបគោលនយោបាយពីមូលនិធិជនពិការជូនជនពិការ |
| យោបល់ | |

## ១៥. ការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន

| ឈ្មោះសេវា | ការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន |
|---|---|
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានស្តារសម្បទា<br>❖ នាយកដ្ឋានសុខុមាលភាពជនពិការ<br>ការិយាល័យស្តារលទ្ធភាពពលកម្ម |

| | |
|---|---|
| | ហត់ឡាញ៖ ១២៧០<br>លេខទូរស័ព្ទ៖ ០១២ ៥៦០ ៨៤៩<br>អាសយដ្ឋាន៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |
| គោលបំណង<br>នៃការផ្តល់សេវា | ការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និង សិទ្ធិជាមូលដ្ឋាន មានគោលបំណងដើម្បី៖<br>• រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មពិការភាពឱ្យមានបទដ្ឋានរួមមួយ ប្រកបដោយ សង្គតិភាព តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព សម្រាប់ជាមូលដ្ឋាន កំណត់ក្រុមគោលដៅជនមានពិការភាព ក្នុងការលើកកម្ពស់ជីវភាព ការទទួលបានសេវាសង្គម ការអភិវឌ្ឍដល់ជនមានពិការភាព និងប្រើប្រាស់ជាទិន្នន័យសម្រាប់កំណត់ក្រុមគោលដៅរបស់កម្មវិធី និងរបបក្នុងប្រព័ន្ធគាំពារសង្គម។<br>• ផ្តល់បណ្ណសម្គាល់ជនមានពិការភាព ដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព ក្នុងការ ទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម និងសេវាសង្គមផ្សេងទៀត ប្រកបដោយសមធម៌ និង បរិយាបន្ន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ២០២អនក្រ.បក. ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន<br>• ប្រកាសលេខ ២២៧ស.អ.យ.ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យប្រើប្រាស់បណ្ណសម្គាល់ជនមានពិការភាព<br>• ប្រកាស លេខ២១៧ស.អ.យ.ប្រក. ចុះថ្ងៃទី២៨ ខែសីហាឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការឯកសារស្តីពីគោលការណ៍ណែនាំអំពីការកំណត់អត្តសញ្ញាណ-កម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន |
| អតិថិជនដែលមាន<br>សិទ្ធិទទួលសេវា | ជនមានពិការភាពក្នុងព្រះរាជាណាចក្រកម្ពុជា |
| ស្តង់ដារសេវា | • ជនមានពិការភាព ដែលចូលរួមសម្ភាសក្នុងការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និង សិទ្ធិជាមូលដ្ឋាន ត្រូវបានវាយតម្លៃតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ដើម្បីទទួលបានបណ្ណសម្គាល់ជនមានពិការភាព ទៅតាមប្រភេទ និងកម្រិតពិការភាព។<br>• ប្រភេទពិការភាព ចែកចេញជា ៥ ប្រភេទ រួមមាន ៖<br>- ពិការភាពកាយសម្បទា<br>- ពិការភាពញាណដឹង<br>- ពិការភាពសតិបញ្ញា<br>- ពិការភាពផ្លូវចិត្ត |

| | |
|---|---|
| | - ពិការភាពផ្សេងៗ<br>• ប្រភេទពិការភាពនីមួយៗ ចែកចេញជា ៣ កម្រិត រួមមាន ៖<br>- កម្រិត១ (កម្រិតធ្ងន់បំផុត និងធ្ងន់)<br>- កម្រិត២ (កម្រិតមធ្យម)<br>- កម្រិត៣ (កម្រិតស្រាល)។ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ១. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត និង<br>២. សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ |
| យោបល់ | |

## ១៦. ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន

| ឈ្មោះសេវា | សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន |
|---|---|
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានស្តារសម្បទា<br>❖ នាយកដ្ឋានគាំពារអ្នកញៀនគ្រឿងញៀន<br>ការិយាល័យអធិការកិច្ចសេវាស្តារនីតិសម្បទា<br>លេខទូរស័ព្ទ ០៧០ ៤០៦ ០៤៩ /០១៥ ៦១៩ ៩១៦<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>- មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទីតាំងស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល<br>លេខទូរស័ព្ទ ០១៥ ២០៣ ៣២៦<br>- មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ<br>លេខទូរស័ព្ទ ០៨១ ៤០៤ ៥០៥<br>- មជ្ឈមណ្ឌលឱកាសខ្ញុំរាជធានីភ្នំពេញ ទីតាំងស្ថិតនៅភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>លេខទូរស័ព្ទ ០១២ ៤២៧ ១៦៨<br>- មជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទីតាំងស្ថិតនៅភូមិជ្រៃ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប<br>លេខទូរស័ព្ទ ០១២ ៦៦៤ ៧៤៧<br>- មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ ទីតាំងស្ថិតនៅភូមិភ្នំបាក់ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ<br>លេខទូរស័ព្ទ ០១២ ២១២ ១៧១ |

| | |
|---|---|
| | - មជ្ឈមណ្ឌលពិភពនៃក្ដីសង្ឃឹម ទីតាំងស្ថិតនៅភូមិដំណាក់ដង្កោ ឃុំក្ដុលតាហែន ស្រុកបវេល ខេត្តបាត់ដំបង<br>លេខទូរស័ព្ទ ០៦៧ ៦៤៩ ៩២១ |
| គោលបំណងនៃការផ្ដល់សេវា | ផ្ដល់ការស្នាក់បណ្ដោះអាសន្នជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅក្នុងមជ្ឈមណ្ឌលជាតិ និងមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ ដើម្បីបន្សាប ព្យាបាលស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ ដោយអនុវត្តកម្មវិធីថែទាំបន្ត |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២<br>• អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អនុក្រឹត្យលេខ ១៦២ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្ដីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាល និងស្ដារនីតិសម្បទាគ្រឿងញៀន<br>• អនុក្រឹតលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្ដីពីរបបគោលនយោបាយ ចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• អនុក្រឹតលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្ដីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ<br>• ប្រកាសលេខ២៨៩ ស.អ.យ. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃអគ្គនាយកដ្ឋានស្ដារនីតិសម្បទា<br>• ប្រកាសលេខ ៦៣៤ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមជ្ឈមណ្ឌលជាតិព្យាបាល និង ស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>• ប្រកាសអន្តរក្រសួងលេខ៩៦៥ ស.អ.យ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល<br>• ស្ដីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំបង្កើតមជ្ឈមណ្ឌលសម្រាប់ការព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>• ប្រកាសលេខ ២៥៣ ស.អ.យ. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ស្ដីពីការអនុវត្តរបបឧបត្ថម្ភគោលនយោបាយជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលអប់រំ បន្សាប ព្យាបាល និងស្ដារនីតិសម្បទា<br>• សារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៣ សរ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្ដីពីការអនុវត្តវិធានការអប់រំ ព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>• សារាចរណែនាំរបស់រដ្ឋាភិបាលលេខលេខ ០៥ សរណន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ស្ដីពីការពង្រឹងការ អនុវត្តវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់<br>• គោលការណ៍ណែនាំរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលេខ ០០២ |

| | |
|---|---|
| | • ស.ណ.ន.អ.ជ.ប.គ.ញ. ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣ សម្រាប់ចាត់តាំងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន<br>• លិខិតលេខ០០៤/១១ធ.ត.អ.ជ.ប.គ.ញ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន<br>• គោលការណ៍ណែនាំស្តីពីការព្យាបាលស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ចុះខែធ្នូ ឆ្នាំ ២០១៧ របស់គណៈកម្មាការទទួលបន្ទុកការងារព្យាបាល និងស្តានីតិសម្បទាអ្នកញៀនគ្រឿងញៀន |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលមានប្រភពមកពី៖<br>• ការស្ម័គ្រចិត្ត<br>• ឪពុកម្តាយ ឬអាណាព្យាបាល ឬអាជ្ញាធរមានសមត្ថកិច្ច<br>• ស្ថាប័នអយ្យការ ឬតុលាការ<br>• ទទួលបានសេវាអប់រំ បន្សាប ព្យាបាល ស្តារនីតិសម្បទា អប់រំផ្លូវចិត្ត បំណិនជីវិត<br>• កិច្ចការហត្ថកម្ម ពលកម្ម កីឡា បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ<br>• ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនត្រូវទទួលរបបតាមអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ សម្រាប់តែមជ្ឈមណ្ឌលរបស់រដ្ឋ<br>• ក្រោយពីបញ្ចប់កម្មវិធីស្តារនីតិសម្បទាត្រូវបានបញ្ចេញ ឬសមារណកម្មទៅក្រុមគ្រួសារ ឬសហគមន៍វិញ |
| ស្តង់ដារសេវា | ដំណាក់កាលនៃការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនមានដូចខាងក្រោម៖<br>**១. ចាប់ពីថ្ងៃចូល ដល់ខែទី០៣**<br>- វាយតម្លៃ និងធ្វើរោគវិនិច្ឆ័យ<br>- ព្យាបាលបន្សាប និងព្យាបាលជំងឺរួមផ្សំ<br>- ថែទាំបន្ត ផ្តល់ប្រឹក្សា អប់រំផ្លូវចិត្ត<br>- ធ្វើផែនការស្តារនីតិសម្បទា<br>**២. ចាប់ពីខែទី០៤ ដល់ខែទី០៦**<br>- ថែទាំបន្ត (ផ្តល់ប្រឹក្សា អប់រំផ្លូវចិត្ត)<br>- ចាប់ផ្តើមស្តារនីតិសម្បទា<br>**៣. ចាប់ពីខែទី០៦ ដល់ខែទី០៩**<br>- ថែទាំបន្ត (ផ្តល់ប្រឹក្សា អប់រំផ្លូវចិត្ត)<br>- ការស្តារនីតិសម្បទា<br>- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ<br>- ការធ្វើផែនការសមាហរណកម្ម<br>**៤. ចាប់ពីខែទី៩**<br>- ការបណ្តុះបណ្តាលបន្ត<br>- ការធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ<br>- តាមដានបន្ត ឬបិទករណី |

| | |
|---|---|
| តម្រូវការឯកសារដើម្បីទទួលបានសេវា | មជ្ឈមណ្ឌលអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាទាំងអស់ អនុវត្តដូចខាងក្រោម៖<br>**ក.ការបញ្ចូលជនរងគ្រោះដើម្បីទទួលសេវា**<br>១. ពាក្យស្នើសុំបញ្ចូលជនរងគ្រោះក្នុងមជ្ឈមណ្ឌល<br>២. បញ្ជីឈ្មោះជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលត្រូវស្នើសុំបញ្ចូលក្នុងមជ្ឈមណ្ឌល<br>៣. កំណត់ហេតុ ឬលិខិតប្រគល់ ទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន<br>៤. កិច្ចសន្យារបស់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន<br>៥. កិច្ចសន្យាអាណាព្យាបាល<br>៦. ប្រវត្តិរូបសង្ខេបរបស់ជនរងគ្រោះ<br>៧. ប្រកាសបញ្ចូលជនរងគ្រោះ<br>**ខ.ការបញ្ចេញជនរងគ្រោះ ឬសមាហរណកម្មជនរងគ្រោះ**<br>១. ពាក្យស្នើសុំបញ្ចេញជនរងគ្រោះពីមជ្ឈមណ្ឌល<br>២. បញ្ជីឈ្មោះជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលត្រូវស្នើសុំបញ្ចេញពីមជ្ឈមណ្ឌល<br>៣. សេចក្តីចម្លងប្រកាសបញ្ចូលជនរងគ្រោះ<br>៤. សំបុត្រមរណភាព (ករណីជនរងគ្រោះទទួលមរណភាព)<br>៥. លិខិតយល់ព្រមទទួលរបស់គ្រួសារ សាច់ញាតិ ឬអាជ្ញាធរមូលដ្ឋាន<br>៦. ប្រកាសបញ្ចេញជនរងគ្រោះ |
| នីតិវិធីនៃការផ្តល់សេវា | ការស្តារនីតិសម្បទាអាចចាប់ផ្តើមបន្ទាប់ពីបញ្ចប់ការវាយតម្លៃរបស់គ្រូពេទ្យហើយ ដំណាក់កាលការចាប់ផ្តើមការស្តារនីតិសម្បទាមានដូចខាងក្រោម ៖<br>• ការពិគ្រោះយោបល់ អប់រំផ្លូវចិត្ត បំណិនជីវិត(**សកម្មភាពមានរយៈពេល ៦សប្តាហ៍**)<br>• ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ រយៈពេលខ្លីពី៣ខែ ឬ**រយៈពេលវែងពី ៦ខែទៅ ១២ខែ**<br>• ការធ្វើសមាហរណកម្ម បន្ទាប់ពីការស្តារនីតិសម្បទា និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបានបញ្ចប់<br>• តាមដាន និងថែទាំបន្ត មានរយៈពេល ១ខែដំបូង ៣ខែ ៦ខែ និង១២ខែ ក្រោយពីសមាហរណកម្ម<br>• បិទករណីចំពោះអតិថិជនអាចទុកចិត្តមិនត្រឡប់ទៅប្រើប្រាស់គ្រឿងញៀនវិញ ឬអតិថិជនផ្លាស់ប្តូរទីលំនៅដោយមិនបានផ្តល់ព័ត៌មាន (ក្នុងគ្រ ប់ដំណាក់កាល បើរកឃើញថាអតិថិជនបានត្រឡប់ប្រើប្រាស់គ្រឿងញៀនវិញ មន្ត្រីសង្គមកិច្ចត្រូវសហការជាមួយក្រុមគ្រួសារ អាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំផែនការឱ្យអតិថិជនទៅទទួលសេវាព្យាបាល និងស្តារនីតិសម្បទាឡើងវិញ) |
| យោបល់ | - ជំរុញលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ អាណាព្យាបាល អប់រំ ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀននៅក្នុងមូលដ្ឋានរបស់ខ្លួន និងបញ្ជូនជនរងគ្រោះដោយសារប្រើប្រាស់គ្រឿងញៀនមកទទួលសេវាអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាតាមមជ្ឈមណ្ឌល និងនៅតាមសហគមន៍។ |

| | |
|---|---|
| | - របបឧបត្ថម្ភគោលនយោបាយសម្រាប់ជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរដ្ឋ គួរតែពិនិត្យសិក្សាអោយស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន |

## ១៧. ការផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់

| | |
|---|---|
| ឈ្មោះសេវា | ការស្តារនីតិសម្បទាដល់អនីតិជនទំនាស់នឹងច្បាប់ការបង្វែរ គ្រប់គ្រងករណី និងសមាហរណកម្ម |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អគ្គនាយកដ្ឋានស្តារសម្បទា<br>❖ នាយកដ្ឋានស្តារនីតិសម្បទាអនីតិជន<br>ការិយាល័យបង្វែរអនីតិជន<br>លេខទូរស័ព្ទ ០១៧ ៨៧៧ ៩៧០ /០១៧ ៨២១ ១២៣<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>❖ មណ្ឌលយុវនីតិសម្បទា ទីតាំងស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល<br>លេខទូរស័ព្ទ ០៦១ ៩៥៨ ៦៩៥ |
| គោលបំណងនៃការផ្តល់សេវា | • ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស<br>• គាំទ្រដល់ការស្តារនីតិសម្បទា អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើ<br>• សមាហរណកម្ម អនីតិជនទៅក្នុងសង្គម និងសហគមន៍<br>• ធានាការពារផលប្រយោជន៍សង្គម និងសហគមន៍ ។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦<br>• អនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• អនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា<br>• ប្រកាសលេខ១៥៥ ស.អ.យ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមណ្ឌលយុវនីតិសម្បទា<br>• ប្រកាសលេខ០៦៧ ស.អ.យ. ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ស្តីពីការបង្កើត |

| | |
|---|---|
| | គណៈកម្មការជ្រើសរើសភ្នាក់ងារសង្គមកិច្ច<br>• ប្រកាសលេខ២៨៩ ស.អ.យ. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាន និងអង្គភាពក្រោមឪវាទនៃអគ្គនាយកដ្ឋានស្តារសម្បទា<br>• ប្រកាសលេខ១២៨ ស.អ.យ. ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា (SOP)<br>• ប្រកាសលេខ២៧៦ ស.អ.យ. ចុះថ្ងៃ ២៤ ខែ ឧសភា ឆ្នាំ២០២៣ ស្តីពីការសម្រួលសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃកម្រិតកែប្រែរបស់ទណ្ឌិតនៅមណ្ឌលយុវនីតិសម្បទា<br>• ប្រកាសលេខ១៤៨ ដល់១៧២ ស.អ.យ. ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងភ្នាក់ងារសង្គមកិច្ច<br>• ប្រកាសលេខ២២០ ស.អ.យ. ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច<br>• ប្រកាសលេខ២២១ ស.អ.យ. ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច (ថ្នាក់កណ្តាល)<br>• សេចក្តីសម្រេចលេខ០១៣ ស.អ.យ. ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ២០២១ ស្តីពីការដាក់អោយប្រើប្រាស់គោលការណ៍ណែនាំដែលទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>• សេចក្តីសម្រេចលេខ២៧៨ ស.អ.យ. ចុះថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពក្រុមការងាររៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងពាក់ព័ន្ធលិខិតបទដ្ឋានគតិយុត្ត នីតិវិធីនៃការគ្រប់គ្រង ការផ្ទេរ ការប្រគល់ និងចំណាត់ថ្នាក់សន្តិសុខ ក្នុងមណ្ឌលយុវនីតិសម្បទា |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • អនីតិជនទំនាស់នឹងច្បាប់ដែលបញ្ជូនដោយតុលាការ<br>• អនីតិជនទំនាស់នឹងច្បាប់ដែលបញ្ជូនដោយមន្ត្រីនគរបាលយុត្តិធម៌ |
| ស្តង់ដារសេវា | ក.អនីតិជនទំនាស់នឹងច្បាប់ដែលអនុវត្តតាមដីកា និងសាលក្រមបង្គាប់ឱ្យឃុំខ្លួនរបស់អាជ្ញាធរតុលាការក្នុងមណ្ឌលយុវនីតិសម្បទា និងទទួលបានការផ្តល់សេវានានារហូតដល់អាយុក្រោម ២៤ឆ្នាំ ៖<br>១. ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា<br>- ផ្នែកឃុំខ្លួនអនីតិជនបណ្តោះអាសន្ន<br>- ផ្នែកឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា<br>- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជនដើម្បីទទួលកម្មវិធីសមាហរណកម្ម<br>២. ការរក្សាទុកអនីតិជន<br>- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន |

| | |
|---|---|
| | - តាមភេទ អាយុ អត្តចរិក សុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់អនីតិជន តាមប្រភេទ និង ស្ថានភាពនៃបទល្មើស<br>- អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា<br>- នៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែក សម្រាប់អនីតិជនដែលមានជំងឺឆ្លង<br>**ខ.**អនីតិជនទំនាស់នឹងច្បាប់ដែលទទួលបានការបង្វែរអនីតិជនអាយុក្រោម ១៤ឆ្នាំអនីតិជនដែលចេញសេចក្តីព្រមានរបស់មន្ត្រីនគរបាលយុត្តិធម៌ និងអនីតិជនដែលដោះលែងដោយមានលក្ខខណ្ឌ ឬធ្វើសមាហរណកម្ម៖<br>- អនីតិជនដែលទទួលបានការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ<br>- អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស<br>- អនីតិជនដែលប្រព្រឹត្តបទល្មើសហើយទទួលបានការព្រមានជាលាយ<br>- ល័ក្ខអក្សរ ឬផ្ទាល់មាត់ពីមន្ត្រីយុត្តិធម៌<br>- អនីតិជនដែលធ្វើសមាហរណកម្ម ឬដោះលែងដោយមានលក្ខខណ្ឌ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | **ក.** ឯកសារគតិយុត្តចេញដោយអាជ្ញាធរតុលាការ<br>១. ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន<br>២. សាលក្រមស្ថាពររបស់តុលាការ<br>៣. ឯកសារពាក់ព័ន្ធនឹងសំណុំរឿង<br>**ខ.** ទម្រង់គ្រប់គ្រងករណីអនីតិជនទំនាស់នឹងច្បាប់មាន<br>១. ព័ត៌មានបឋម<br>២. ការប៉ាន់ប្រមាណករណី និងគ្រួសារ<br>៣. ផែនការសេវាសម្រាប់ករណី និងគ្រួសារ<br>៤. ការទុកដាក់អនីតិជន<br>៥. តាមដាន និងត្រួតពិនិត្យ<br>៦. ប៉ាន់ប្រមាណចុងក្រោយ<br>**គ.** ទម្រង់របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់នីតិជន<br>**ឃ.** ទម្រង់ផែនការបង្វែរ( សម្រាប់អនីតិជនដែលត្រូវទទួលបានការបង្វែរ) |
| នីតិវិធីនៃការផ្តល់សេវា | **១.សេវាផ្តល់ឱ្យអនីតិជនដែលកំពុងស្នាក់នៅក្នុងមណ្ឌល៖**<br>- ពិនិត្យវាយតម្លៃសុខភាពផ្លូវកាយ ផ្លូវចិត្តដោយគ្រូពេទ្យ<br>- ពិគ្រោះយោបល់ អប់រំផ្លូវចិត្ត<br>- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កម្សាន្ត កីឡា<br>- ផ្តល់កម្មវិធីសមាហរណកម្ម<br>- សេវាកម្មផ្សេងៗទៀត<br>អនីតិជនទំនាស់នឹងច្បាប់ត្រូវទទួលបានរបបតាមអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥<br>**២.សេវាផ្តល់អោយអនីតិជនក្នុងសហគមន៍** |

| | |
|---|---|
| | - ការរៀបចំ និងការអនុវត្តផែនការបង្វែរ<br>- ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការសិក្សាអប់រំ<br>- ការគ្រប់គ្រងករណី<br>- សហការផ្តល់សេវាចាំបាច់នានាជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ដោយភ្ជាប់ជាមួយឯកសារគតិយុត្តត្រឹមត្រូវ |
| យោបល់ | ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវផ្តល់សេវាជំនាញពេញលេញរបស់ខ្លួនដើម្បីធ្វើយ៉ាងណាឱ្យសេវាទាំងនោះអាចឱ្យអនីតិជនប្រកបរបរវិជ្ជាជីវៈបាន បន្ទាប់ពីបានដោះលែង ឬសមាហរកម្មវិលត្រលប់ទៅក្នុងក្រុមគ្រួសារ ឬសហគមន៍វិញ។<br><br>អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធត្រូវលើកស្ទួយការផ្សព្វផ្សាយច្បាប់បទដ្ឋានគតិយុត្តផ្សេងៗ ពិសេសច្បាប់ស្តីពីយុត្តិធម៌អនីតិជនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន និងចូលរួមអនុវត្តកម្មវិធីបង្វែរដើម្បីកាត់បន្ថយការអនុវត្តនីតិវិធីតុលាការនិងទប់ស្កាត់ការប្រព្រឹត្តបទល្មើសសារជាថ្មីរបស់អនីតិជន។ |

## ផ្នែកទី៣. អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

### ១៨. ការផ្តល់ការអនុញ្ញាត (អាជ្ញាបណ្ណ)ដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

| ឈ្មោះសេវា | ការផ្តល់ការអនុញ្ញាត(អាជ្ញាបណ្ណ)ដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| --- | --- |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>❖ រដ្ឋបាលសុំកូនអន្តរប្រទេស<br>អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ: ០២៣ ២១១ ៨៤៨/០១៦ ២៧០ ៧៣៦<br>អ៊ីម៉ែល: info@icaa-cambodia.gov.kh<br>គេហទំព័រ: www.icaa-cambodia.gov.kh |
| គោលបំណងនៃការផ្តល់សេវា | ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលដែលទទួលបានការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា |
| មូលដ្ឋានគតិយុត្ត | - អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២<br>- ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស<br>- ព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស<br>- ប្រកាសរួមលេខ១០០៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសលេខ១១៥ ស.អ.យ. ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | - ទីភ្នាក់ងារដែលមានការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសរបស់ទីភ្នាក់ងារ<br>- ទីភ្នាក់ងារមានការអនុញ្ញាតពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសរបស់ទីភ្នាក់ងារ ឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា<br>- ទីភ្នាក់ងារនីមួយៗ ត្រូវចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ទីភ្នាក់ងារមិនមានបើកមណ្ឌលកុមារកំព្រា ឬប្រើប្រាស់មណ្ឌលកុមារកំព្រាដើម្បីជាប្រភពផ្តល់ទារក និងកុមារកំព្រាសម្រាប់សុំកូនអន្តរប្រទេស |

<table>
<tr><td></td><td>- ប្រទេសរបស់ទីភ្នាក់ងារជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។</td></tr>
<tr><td>ស្តង់ដារសេវា</td><td>តម្លៃសេវាសម្រាប់ការផ្តល់ ឬបន្តសុពលភាពអាជ្ញាប័ណ្ណស្មុំកូនអន្តរប្រទេស រយៈពេលផ្តល់ និងសុពលភាពអាជ្ញាប័ណ្ណត្រូវកំណត់ ដូចខាងក្រោម៖<br>
<table>
<tr><th>ល.រ</th><th>បរិយាយ</th><th>តម្លៃសេវា(៛)</th><th>សុពលភាព</th></tr>
<tr><td>១</td><td>ការផ្តល់អាជ្ញាបណ្ណ</td><td>១២.០០០.០០០</td><td>២ ឆ្នាំ</td></tr>
<tr><td></td><td>សេវារដ្ឋបាលពិនិត្យសំណុំឯកសារ</td><td>២.០០០.០០០</td><td></td></tr>
<tr><td></td><td>សេវាផ្តល់អាជ្ញាបណ្ណ</td><td>១០.០០០.០០០</td><td></td></tr>
<tr><td>២</td><td>បន្តសុពលភាពអាជ្ញាបណ្ណ</td><td>២.០០០.០០០</td><td>២ ឆ្នាំ</td></tr>
</table>
នីតិវិធីនៃការដាក់ពាក្យសុំអនុញ្ញាតជាទីភ្នាក់ងារ៖<br>
- ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារស្មុំកូនអន្តរប្រទេសទាំងអស់ត្រូវបញ្ជូន តាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់ទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលមានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះហើយបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពិនិត្យ និងបញ្ជូនបន្តទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាស្ថាប័នពិនិត្យ និងសម្រេចចុងក្រោយ។<br>
- សំណុំឯកសារទាំងអស់របស់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេស ត្រូវមានជាភាសាអង់គ្លេស ឬភាសាបារាំង ហើយត្រូវបកប្រែជាខេមរភាសាតាមរយៈក្រុមហ៊ុនឬអង្គភាពដែលមានការទទួលស្គាល់ជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។</td></tr>
<tr><td>តម្រូវការឯកសារដើម្បីទទួលបានសេវា</td><td>សំណុំឯកសារដើម្បីទទួលបានការអនុញ្ញាតជាទីភ្នាក់ងារស្មុំកូនអន្តរប្រទេសមានដូចខាងក្រោម៖<br>
១. ពាក្យស្នើសុំការអនុញ្ញាតត្រូវចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារ។<br>
២. ច្បាប់ចម្លងវិញ្ញាបនប័ត្រទទួលស្គាល់គុណវុឌ្ឍិរបស់ទីភ្នាក់ងារ(នៅមានសុពលភាព) ដែលមានការបញ្ជាក់ត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច។<br>
៣. ច្បាប់ចម្លងលិខិតអនុញ្ញាតឱ្យបើកទីភ្នាក់ងារ ដែលមានទិសដៅមិនស្វែងរកផលចំណេញ ចេញដោយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ។<br>
៤. លិខិតរបស់អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស នៃប្រទេសរបស់ទីភ្នាក់ងារដែលអនុញ្ញាតឱ្យទីភ្នាក់ងារមកធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជា។<br>
៥. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ។<br>
៦. ប្រវត្តិសង្ខេបអំពីសកម្មភាព កម្មវិធី និងសេវាកម្មរបស់ទីភ្នាក់ងារ ដែលមានបទពិសោធន៍ក្នុងការងារស្មុំកូនអន្តរប្រទេសយ៉ាងតិច ០៥ឆ្នាំ។<br>
៧. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយដែលបានធ្វើសវនកម្មឯករាជ្យរួមមានប្រភពមូលនិធិ សោហ៊ុយស្មុំកូន និងថ្លៃចំណាយនានា ទាក់ទងនឹងស្មុំកូនអន្តរប្រទេស។<br>
៨. ជីវប្រវត្តិសង្ខេបរបស់ប្រធានទីភ្នាក់ងារ មានបិទរូបថតទំហំ ៤ ស.ម. x ៦ ស.ម.។</td></tr>
</table>

| | |
|---|---|
| | ៩. ជីវប្រវត្តិសង្ខេបរបស់បុគ្គលមួយនាក់ ឬ ពីរនាក់ជាអ្នកតំណាងទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជា មានបិទរូបថតទំហំ ៤ ស.ម. x ៦ ស.ម.។<br>១០. លិខិតថ្កោលទោសរបស់អ្នកតំណាងទីភ្នាក់ងារជាជនជាតិខ្មែរ(នៅមានសុពលភាព) ចំពោះជាអ្នកតំណាងទីភ្នាក់ងារជាជនជាតិបរទេសត្រូវមានលិខិតបញ្ជាក់ថាពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬកំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមណាមួយនៅក្នុងប្រទេសដើមរបស់ខ្លួន ឬក្នុងប្រទេសណាមួយដែលខ្លួនកំពុងស្នាក់នៅចុងក្រោយ។<br>១១.កិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេសរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងករណីដែលប្រទេសនោះមិនមែនជារដ្ឋភាគីនៃអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស។<br>១២.ឯកសារផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់ សម្រាប់ជាមូលដ្ឋានវាយតម្លៃពាក្យស្នើសុំឱ្យបានសមស្របដើម្បីជាឧត្តមប្រយោជន៍កុមារ។ |
| យោបល់ | |

## ១៩. ការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល

| | |
|---|---|
| ឈ្មោះសេវា | ការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>❖ រដ្ឋបាលសុំកូនអន្តរប្រទេស<br>អាសយដ្ឋាន: អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ: ០២៣ ២១១ ៨៤៨/០១៦ ២៧០ ៧៣៦<br>អ៊ីម៉ែល: info@icca-cambodia.com.kh<br>គេហទំព័រ: www.icaa-cambodia.com.kh |
| គោលបំណង នៃការផ្តល់សេវា | ការផ្តល់សេវាដល់កុមារឱ្យទទួលបាននូវឋានៈ សិទ្ធិ និងកាតព្វកិច្ច ដូចជាកូនបង្កើត អាចបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍រវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមស្របច្បាប់នៃប្រទេសទទួល |
| មូលដ្ឋានគតិយុត្ត | - អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២<br>- ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស |

| | |
|---|---|
| | - ព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស<br>- ប្រកាសរួម ៤៤៨ សហវ-ប្រក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ស្តីពីការកំណត់ចំនួនប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស<br>- ប្រកាសលេខ ១៩៤ ស.អ.យ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា<br>- ប្រកាសលេខ ១៩៩ ស.អ.យ. ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>- ប្រកាសលេខ ១៣៨ ស.អ.យ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ<br>- ប្រកាសលេខ ១៣៩ ស.អ.យ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ១. <u>កូនសុំ</u><br>**លក្ខខណ្ឌកុមារដែលអាចជាកម្មវត្ថុសម្រាប់សុំកូនអន្តរប្រទេស៖**<br>- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា មានអាយុក្រោម៨ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម១៨ឆ្នាំ។ ក្នុងករណីកុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម៨ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម១៨ឆ្នាំ<br>- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀតដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬកុមារដែលស្ថិតក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត<br>- ក្នុងករណីសុំកូនដោយសាច់ញាតិសុំកូនអាចអនុញ្ញាតឱ្យបានចំពោះកុមារមានអាយុក្រោម១៨ ឆ្នាំដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា។<br>២ .<u>អ្នកសុំ</u><br>**លក្ខខណ្ឌអ្នកសុំដែលអនុញ្ញាតឱ្យសុំកុមារយកទៅចិញ្ចឹមជាកូន៖**<br>- អ្នកសុំ (ឪពុកម្តាយចិញ្ចឹម) ជាសហព័ទ្ធដែលមានបំណងសុំកូននៅកម្ពុជា (ទាក់ទងការដាក់ពាក្យសុំកូនតាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលនៃប្រទេសទទួល) ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅ<br>- ក្នុងប្រទេសណាមួយផ្សេងទៀតដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា<br>- អ្នកសុំត្រូវមានលក្ខណសម្បត្តិ និងលក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របតាមច្បាប់ប្រទេសទទួល និងប្រទេសដើម |

| | |
|---|---|
| | - អ្នកសុំមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន<br>- អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបានលុះត្រាតែអ្នកសុំកូនគ្មានកូន ឬមានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន។ |
| ស្តង់ដារសេវា | **I.ប្រាក់ចំណាយ សោហ៊ុយ វិភាគទាននានាសម្រាប់ស្មុំកូនអន្តរប្រទេស**<br>- អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាចំនួន ៥.០០០ USD (ប្រាំពាន់ដុល្លារអាម៉េរិក) ក្នុងការសុំកូន ០១(មួយ)នាក់ តាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃប្រទេសទទួល។ ការបង់ប្រាក់នេះ ត្រូវចែកជាពីរដំណាក់កាល៖<br>- ដំណាក់កាលទី១៖ អ្នកសុំត្រូវបង់ប្រាក់ចំនួន ១.៥០០ USD (មួយពាន់ប្រាំរយដុល្លារអាម៉េរិក) នៅពេលសំណុំឯកសារស្មុំកូនត្រូវបានបញ្ជូនមកដល់រដ្ឋបាលស្មុំកូនអន្តរប្រទេសនៃអាជ្ញាធរកណ្តាល ស្មុំកូនអន្តរប្រទេស។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញបានទេ។<br>- ដំណាក់កាលទី២៖ អ្នកសុំត្រូវបង់ប្រាក់ចំនួន ៣.៥០០ USD (បីពាន់ប្រាំរយដុល្លារអាម៉េរិក) នៅមុនពេលធ្វើពិធីប្រគល់កុមារជាផ្លូវការ។<br>- ក្រៅពីការបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាខាងលើនេះអ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០(មួយលាន) រៀល តាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំការពិនិត្យភ័ស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយ សេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗទៀតដែលទាក់ទងនឹងកិច្ចការស្មុំកូនអន្តរប្រទេស។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះលើសពី ១.០០០.០០០(មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។<br>**II.នីតិវិធីនៃការដាក់ពាក្យសុំកូនអន្តរប្រទេស**<br>- អ្នកសុំត្រូវដាក់ពាក្យសុំ តាមរយៈទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ របស់អ្នកសុំ ដែលបានផ្តល់ការអនុញ្ញាតអោយធ្វើប្រតិបត្តិការការងារស្មុំកូនអន្តរប្រទេសនៅ ព្រះរាជាណាចក្រកម្ពុជា ឬ អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកស្មុំកូនអន្តរប្រទេស ហើយសំណុំឯកសារទាំងអស់ត្រូវបញ្ជូនទៅស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ។ បន្ទាប់មកស្ថានទូត ឬ ស្ថានតំណាងត្រូវបញ្ជូនសំណុំឯកសារ |

| | |
|---|---|
| | ទាំងនោះមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីត្រួតពិនិត្យផ្តល់យោបល់ និងត្រូវបញ្ជូនសំណុំឯកសារមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ សំណុំឯកសារទាំងអស់ ត្រូវមានជាភាសាអង់គ្លេស ឬភាសាបារាំង ហើយត្រូវបកប្រែជាភាសាខ្មែរ។<br>III.**ឯកសារសម្រាប់កុមារអាចទទួលបានការអនុញ្ញាតរស់នៅស្របច្បាប់ក្នុងគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល**<br>- ដីកាសម្រេចដោយតុលាការរាជធានីភ្នំពេញ លើករណីសុំកូនអន្តរប្រទេស<br>- លិខិតបញ្ជាក់សុំកូនអន្តរប្រទេសដែលចេញដោយអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | **សំណុំឯកសារអ្នកសុំ៖**<br>១.ពាក្យសុំកូន<br>២.លិខិតអនុញ្ញាតឱ្យសុំកូនចិញ្ចឹមចេញដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំដោយមានបញ្ជាក់ថាកូនសុំត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសរបស់អ្នកសុំនៅពេលដែលដំណើរការសុំកូនបានសម្រេចជាផ្លូវការ។<br>៣.របាយការណ៍ស្តីពីស្ថានភាពគ្រួសារដែលធ្វើឡើងដោយភ្នាក់ងារជំនាញលើការងារនេះហើយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់អ្នកសុំដោយមានបញ្ជាក់ អំពីសមត្ថភាពរបស់អ្នកសុំផ្នែកធនធានថវិកា សមត្ថភាពផ្លូវចិត្ត និងប្រព័ន្ធគាំទ្រកុមារដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ។<br>៤.សេចក្តីចម្លងសំបុត្រកំណើត ឬលិខិតបញ្ជាក់កំណើត។<br>៥.សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍។<br>៦.លិខិតបញ្ជាក់សុខភាពរបស់អ្នកសុំ។<br>៧.របាយការណ៍អំពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យាដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច។<br>៨.លិខិតបញ្ជាក់ថាអ្នកសុំបានទទួលព័ត៌មានគ្រប់គ្រាន់ និងបានទទួលការប្រឹក្សាយោបល់អំពីការសុំកុមារដែលត្រូវការនូវការថែទាំពិសេស ឬកុមារដែលមានតម្រូវការពិសេសមុនពេលសុំកូន។<br>៩.លិខិតបញ្ជាក់ថាគ្មានទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសកំណើត ឬកន្លែងដែលអ្នកសុំរស់នៅចុងក្រោយ ឬលិខិតថ្កោលទោសចេញដោយតុលាការ ឬដោយអាជ្ញាធរមានសមត្ថកិច្ច ហើយនៅមានសុពលភាពសម្រាប់ប្រើប្រាស់។<br>១០.លិខិតបញ្ជាក់ពីកិរិយាមាយាទនៅកន្លែងប្រកបការងារនិងនៅក្នុងសង្គមរស់នៅរបស់ អ្នកសុំចេញដោយអាជ្ញាធរមានសមត្ថកិច្ច។<br>១១.លិខិតបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់អ្នកសុំដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។<br>១២.កិច្ចសន្យាគោរពសិទ្ធិជាកូនផ្តល់ការសិក្សាព្រមទាំងសិទ្ធិផ្តល់កេរ្តិ៍មរតកដូចកូនបង្កើតរបស់ខ្លួន។ |

| | |
|---|---|
| | ១៣.កិច្ចសន្យាស្តីពីការផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការវិវឌ្ឍរបស់កូនសុំ ទៅកាន់រដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ឬតាមរយៈអាជ្ញាធរកណ្តាលឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសឬតាមរយៈទីភ្នាក់ងារសុំ កូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំរៀងរាល់ ០៦ខែម្តង ក្នុងរយៈពេល ០៣ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ០១ឆ្នាំម្តង រហូតដល់កូនសុំមានអាយុ ១៨ ឆ្នាំ។<br>១៤.ផែនការក្នុងការចិញ្ចឹមកុមារនៅពេលកុមារទៅដល់ប្រទេសទទួល(ដូចជារយៈពេល ដែលអ្នកសុំអាចមានលទ្ធភាពឈប់សម្រាកថែទាំកុមារ)។ផែនការក្នុងការមាន អាណាព្យាបាលមើលថែទាំកុមារក្នុងករណីអ្នកសុំបាត់បង់សមត្ថភាពឬស្លាប់ដោយ ថាហេតុ។<br>១៥.លិខិតបញ្ជាក់ពីមនោសញ្ចេតនា និងការអភិវឌ្ឍសង្គមក្នុងកិច្ចការពារថែទាំកុមារដែល ត្រូវការនូវការថែទាំពិសេស ឬកុមារមានតម្រូវការពិសេស។<br>១៦.ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់អ្នកសុំ។<br>១៧.រូបថតរបស់អ្នកសុំ ៦សម x ៨សម ដែលថតក្នុងអំឡុង ០៣(បី)ខែចុងក្រោយ។<br>១៨.ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអ ចិន្ត្រៃយ៍ របស់អ្នកសុំ។<br>១៩.ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ដែលមានការបញ្ជាក់ត្រឹមត្រូវ។<br>២០.ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ។ |
| យោបល់ | |

## ផ្នែកទី៤. វិទ្យាស្ថានជាតិសង្គមកិច្ច

## ២០. ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពកម្លាំងសេវាសង្គម

| | |
|---|---|
| ឈ្មោះសេវា | បណ្តុះបណ្តាលកម្លាំងសេវាសង្គម |
| ក្រសួងស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>❖ វិទ្យាស្ថានជាតិសង្គមកិច្ច<br>អាសយដ្ឋាន៖ អគារលេខ២០B វិថីឌូងង៉ៀប២ ភូមិជំណាក់៣ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>ទូរស័ព្ទ៖ ០៩៣ ៥៦២ ៨៣៨ / ០១២ ៩៤០ ២៣២<br>ទូរសារអេឡិចត្រូនិច (email) ៖ nisa@nisa-edu.gov.kh<br>វេបសាយ (website) ៖ www.nisa-edu.gov.kh |
| គោលបំណងនៃការផ្តល់សេវា | ពង្រឹងសមត្ថភាពកម្លាំងសេវាសង្គមឱ្យមានកម្រិតចំណេះដឹង និងកម្រិតជំនាញពិតប្រាកដ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈដើម្បីផ្តល់សេវាសង្គមកិច្ចជូនអតិថិជនដែលជាជនរងគ្រោះ និងងាយរងគ្រោះជានាបាននូវប្រសិទ្ធភាពខ្ពស់។ |
| មូលដ្ឋានគតិយុត្ត | ➢ អនុក្រឹត្យលេខ ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច<br>➢ ប្រកាសលេខ ៧២៥ ស.អ.យ. ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិសង្គមកិច្ច<br>➢ សេចក្តីសម្រេចលេខ ២៨ អយក.សសរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបង្កើតដេប៉ាតឺម៉ង់ និងមុខជំនាញនៅវិទ្យាស្ថានជាតិសង្គមកិច្ច ។<br>➢ គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា ចុះថ្ងៃទី២៩ ខែវិច្ឆិកា ២០១៩<br>➢ ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា(ក.គ.ជ.ក) ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៥៣អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤<br>➢ ផែនការមេបណ្តុះបណ្តាលកម្លាំងសេវាសង្គម<br>➢ ផែនការយុទ្ធសាស្ត្រសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គមផ្តោតលើកិច្ចការពារកុមារ ២០២១-២០២៥ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | មន្ត្រីថ្នាក់មន្ទីរ ស.អ.យ. មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារ មន្ត្រីទទួលបន្ទុកការងារ ស.អ.យ. នៃការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ បុគ្គលិកកិច្ចការពារកុមារ នៃអង្គការមិនមែនរដ្ឋាភិបាល គ.ក.ស.ក រាជធានី ខេត្ត គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ, គ.ក.ន.ក ឃុំ សង្កាត់។ |
| ស្តង់ដារសេវា | • វិញ្ញាបនបត្រវិជ្ជាជីវៈ<br>• វិញ្ញាបនបត្រ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ១. ប្រវត្តិរូបសង្ខេប (បិតរូបថត ៤X៦)<br>២. លិខិតបញ្ជាបេសកកម្ម<br>៣. បណ្ណសម្គាល់មន្ត្រីរាជការ ឬលិខិតបញ្ជាក់ការងារពីអង្គភាពស្ថាប័ន |

| យោបល់ | |
|---|---|

## ២១. ការអប់រំ និងបណ្ដុះបណ្ដាលកម្រិតឧត្តមសិក្សា

| ឈ្មោះសេវា | ការអប់រំ និងបណ្ដុះបណ្ដាលកម្រិតឧត្តម ( កម្រិត១ឆ្នាំ ) និង ( កម្រិត៣ឆ្នាំ ) |
|---|---|
